អង្គការសហប្រជាជាតិ

A/HRC/23/48/Add.4

**មហាសន្និបាត**

ផ្សព្វផ្សាយ : ទូទៅ
ថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៣

ច្បាប់ដើម: ភាសាអង់គ្លេស

## ក្រុមប្រឹក្សាសិទ្ធិមនុស្ស

**កិច្ចប្រជុំលើកទី២៣**

របៀបវារៈទី៣

**ការលើកកម្ពស់ និងការការពាររាល់គ្រប់សិទ្ធិមនុស្ស**
**សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម**
**និងសិទ្ធិវប្បធម៌ រួមទាំងសិទ្ធិអភិវឌ្ឍន៍**

# របាយការណ៍ ស្តីពីការជួញដូរមនុស្ស ជាពិសេសលើស្ត្រី និងកុមារ របស់ អ្នករាយការណ៍ពិសេស អ្នកស្រី ចយ ង៉ូហ្ស៊ី អេហ្សីឡូ

**ផ្នែកបន្ថែម**

## កិច្ចពិគ្រោះយោបល់របស់អ្នកជំនាញ ស្តីពីការជួញដូរមនុស្ស និង ខ្សែសង្វាក់ផ្គត់ផ្គង់ផលិតកម្មនៅលើពិភពលោក*

*សេចក្តីសង្ខេប*

បន្ទាប់ពីបទបង្ហាញនៃរបាយការណ៍បណ្តោះអាសន្នរបស់លោកស្រីដល់មហាសន្និបាត ស្តីពីបញ្ហាជួញដូរមនុស្ស និងខ្សែសង្វាក់ផ្គត់ផ្គង់ផលិតកម្មនៅលើពិភពលោក ដែលបានដាក់ជូនដោយមានសេចក្តីសម្រេចនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ១៧/១ (A/៦៧/២៦១) អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសលើស្ត្រី និង

* សេចក្តីសង្ខេបនៃរបាយការណ៍នេះត្រូវបានចែកផ្សាយជាភាសាផ្លូវការទាំងអស់។ របាយការណ៍ទាំងមូលមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃសេចក្តីសង្ខេបនេះ ហើយត្រូវបានចែកផ្សាយជាភាសាដែលបានតម្កល់ទុកតែប៉ុណ្ណោះ។

GE.13-11640

Please recycle

កុមារបានរៀបចំប្រជុំកិច្ចប្រជុំពិគ្រោះយោបល់អន្តរជាតិនៅទីក្រុងអង់ការ៉ា នាថ្ងៃទី១២ និង ១៣ ខែវិច្ឆិកា ឆ្នាំ២០១២ ស្តីពីរបកគំហើញ និងអនុសាសន៍សំខាន់ៗនៅក្នុងរបាយការណ៍របស់លោកស្រី ដើម្បីពិភាក្សាទៅលើធាតុផ្សំសំខាន់ៗសម្រាប់រៀបចំជារង្វាស់មូលដ្ឋាន និងសូចនាករជួយសម្រួលដល់វិស័យធុរកិច្ចយកចិត្តទុកដាក់បានម៉ត់ចត់ទៅលើការទប់ស្កាត់ និងស្រាវជ្រាវរកករណីជួញដូរមនុស្សផ្សេងៗដែលអាចកើតមាននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ផលិតកម្មរបស់ពួកគេ។ កិច្ចពិគ្រោះយោបល់នេះត្រូវបានចូលរួមពីសំណាក់ប្រមុខអ្នកជំនាញការសំខាន់ៗ និងបណ្តាអង្គការប្រឆាំងការជួញដូរមនុស្សនានា ហើយនិងអ្នកតំណាងចំនួន២០រូបមកពីសហគ្រាសធុរកិច្ច សហជីពការងារ អង្គការមិនមែនរដ្ឋាភិបាល បណ្ឌិត្យស្ថាន និងអង្គការអន្តរជាតិនានា។

កិច្ចពិគ្រោះយោបល់នេះបានផ្តោតលើការយល់ដឹងពីទំនាក់ទំនងរវាងការជួញដូរមនុស្ស និងខ្សែសង្វាក់ផ្គត់ផ្គង់ផលិតកម្មនៅលើពិភពលោក ហើយនិងគ្រោះថ្នាក់ ដែលកម្មករ និងស្ថាប័នធុរកិច្ចកំពុងប្រឈម។ ចំពោះបញ្ហានេះ វាគ្មិននានាបានបរិយាយពីក្របខ័ណ្ឌទេសន្តរប្រវេសន៍អន្តរជាតិ ដោយសំដៅដល់ករណីជាក់លាក់នៃការរំលោភបំពាន ដែលកត់ត្រាដោយប្រព័ន្ធផ្សព្វផ្សាយ ទម្រង់ផ្សេងៗនៃការកេងប្រវ័ញ្ចនៅដំណាក់កាលជ្រើសរើស និងដំណាក់កាលធ្វើការហើយនិងកត្តាផ្សេងៗដែលបង្កើននូវភាពងាយរងគ្រោះរបស់ពលករទេសន្តរប្រវេសន៍។

បន្ទាប់មក សិក្ខាកាមបានកំណត់ពីការឆ្លើយតបមួយចំនួននៃសហគមន៍ធុរកិច្ចចំពោះភាពប្រឈមនៃការជួញដូរមនុស្សនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ជាពិសេស ក្រុមហ៊ុនចំនួនពីរបានធ្វើការប្តេជ្ញា និងខិតខំប្រឹងប្រែងត្រួតពិនិត្យលើខ្សែរសង្វាក់ផ្គត់ផ្គង់របស់ខ្លួន និងកាត់បន្ថយហានិភ័យដែលអាចកើតមានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស។ ការឆ្លើយតបមួយចំនួនក៏ត្រូវបានលើកយកមកពិភាក្សាផងដែរ
ដូចជាតួនាទីនៃដំណើរការធ្វើសវនកម្មសង្គម និងការវាយតម្លៃកន្លែងធ្វើការលក្ខខណ្ឌជ្រើសរើស និងការបម្រើការងារនៅក្នុងបណ្តាខ្សែសង្វាក់ផ្គត់ផ្គង់ សារៈសំខាន់នៃការធ្វើការងាររួមគ្នាជាមួយទីភ្នាក់ងារផ្គត់ផ្គង់ផលិតកម្ម (ឧទាហរណ៍៖ តាមរយៈការលើកកម្ពស់ឲ្យមានកម្មវិធីបណ្តុះបណ្តាល និងកសាងសមត្ថភាពជាដើម) តម្រូវការនៃការផ្តួចផ្តើមគំនិតទទួលខុសត្រូវផ្នែកសង្គម ដើម្បីផ្តោតលើការយកចិត្តទុកដាក់ចំពោះអ្នកផ្គត់ផ្គង់សេវាកម្ម (ឧទាហរណ៍៖ ការបង្កើតមជ្ឈមណ្ឌលសេវាកម្មទូរស័ព្ទជាដើម) និងសារៈសំខាន់នៃការផ្តល់ការពិចារណាពិសេសលើសិទ្ធិរបស់ពលករចំណាកស្រុក និងពលករបរទេស ដែលធ្វើការងារតាមរយៈកិច្ចសន្យានៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ផលិតកម្ម។ ទស្សនៈនៃការជ្រើសរើសបុគ្គលិកប្រកបដោយក្រមសីលធម៌ ដែលជាវិធានការថ្មីបង្កើតឡើងនៅក្នុង

ការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្សក៏ត្រូវបានយកមកពិចារណាផងដែរ។ សិក្ខាកាមបានពិភាក្សាគ្នាយ៉ាងច្រើនទៅលើមូលបទស្ដីពីភាពជាដៃគូ និងកិច្ចសន្ទនាដែលប្រធានបទទាំងនេះត្រូវបានចាត់ទុកថាជាសមាសធាតុដ៏សំខាន់សម្រាប់ដោះស្រាយហានិភ័យពាក់ព័ន្ធនឹងការជួញដូរមនុស្សដែលអាចកើតមាននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ផលិតកម្ម។ តាមរយៈមូលបទនេះ កិច្ចពិភាក្សាក៏បានលើកឡើងអំពីបទពិសោធទាំងឡាយទាក់ទងនឹងអង្គការ និងក្រុមហ៊ុននានាដែលបាននិងកំពុងធ្វើការរួមគ្នានៅក្នុងវិស័យនេះ។ បរិបទនៃនិយាមអន្តរជាតិពាក់ព័ន្ធនឹងការចូលរួមរបស់សហគមន៍ធុរកិច្ចក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សដែលអាចកើតមានក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ផលិតកម្មនៅលើពិភពលោកក៏ត្រូវបានរំលឹកឡើងវិញតាមរយៈការពិនិត្យឡើងវិញទៅលើឧបករណ៍សិទ្ធិមនុស្សអន្តរជាតិ និងបទដ្ឋានស្ដីពីកាតព្វកិច្ចរបស់រដ្ឋ និងទំនួលខុសត្រូវរបស់វិស័យធុរកិច្ចផងដែរ។ យុទ្ធសាស្ត្រថ្មីៗ ដែលរួមមានកម្មវិធីបង្កើតថ្មីមួយចំនួន សម្រាប់ធានាការចូលរួមត្រួតពនិត្យខ្សែសង្វាក់ផ្គត់ផ្គង់ផលិតកម្ម ជាពិសេស តួនាទីរបស់អ្នកប្រើប្រាស់នៅក្នុងបរិបទនេះក៏ត្រូវបានលើកយកមកពិចារណាផងដែរ។

ជាចុងក្រោយ សិក្ខាកាមបានសម្លឹងមើលជំហានឆ្ពោះទៅអនាគត ដោយពិនិត្យឡើងវិញជាពិសេសលើសេចក្ដីព្រាងនៃបញ្ជីត្រួតពិនិត្យសូចនាករ និងរង្វាស់មូលដ្ឋាន ដែលសហគ្រាសទាំងឡាយអាចប្រើប្រាស់ដើម្បីប៉ាន់ប្រមាណអំពីហានិភ័យពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងពលកម្មដោយបង្ខំដែលអាចកើតមាននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់ខ្លួន។ សូចនាករ និងរង្វាស់មូលដ្ឋានទាំងនេះមានបំណងបំពេញបន្ថែមលើគំនិតផ្ដួចផ្ដើមសំខាន់ៗដែលមានស្រាប់ ដែលសហគ្រាសខ្លួនឯងផ្ទាល់ និងអង្គការសង្គមស៊ីវិលបានបង្កើតឡើង។ អ្នករាយការណ៍ពិសេសជឿជាក់ថា សូចនាករ និងរង្វាស់មូលដ្ឋានទាំងនេះអាចជាឧបករណ៍ដ៏មានតម្លៃសម្រាប់វិស័យធុរកិច្ច ក្នុងការផ្ដោតការយកចិត្តទុកដាក់ស្រាវជ្រាវ និងទប់ស្កាត់ករណីជួញដូរមនុស្សនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ផលិតកម្មរបស់ខ្លួន ដូចមានលើកឡើងនៅក្នុងគោលការណ៍ណែនាំស្ដីពីការងារធុរកិច្ច និងសិទ្ធិមនុស្ស។ ជាលទ្ធផល អ្នករាយការណ៍ពិសេសយល់ឃើញថាបញ្ជីត្រួតពិនិត្យនេះជាឧបករណ៍ពិតប្រាកដសម្រាប់អភិវឌ្ឍ និងបំពេញបន្ថែមលើគោលការណ៍ណែនាំខាងលើ។ លោកស្រីក៏មានទស្សនៈថា បើទោះបីជាត្រូវធ្វើឡើងដោយស្ម័គ្រចិត្តក៏ដោយ ក៏ការលើកកម្ពស់ឱ្យមានសូចនាករនិងរង្វាស់មូលដ្ឋាន នៅក្នុងអាណត្តិរបស់លោកស្រី អាចជួយសម្រួលដល់កិច្ចខិតខំប្រឹងប្រែងនានាក្នុងការផ្ដោតការយកចិត្តទុកដាក់អំពីការទទួលខុសត្រូវនៃនីតិបុគ្គលទៅលើបញ្ហាសិទ្ធិមនុស្ស ជាពិសេសគឺការជួញដូរមនុស្ស។

# ឧបសម្ព័ន្ធ

*[មានតែជាភាសាអង់គ្លេស]*

## របាយការណ៍របស់អ្នករាយការណ៍ពិសេសអំពីការជួញដូរមនុស្ស ជាពិសេសលើស្ត្រី និងកុមារ នៅក្នុងកិច្ចពិគ្រោះយោបល់អ្នកជំនាញស្តីពីការជួញដូរមនុស្ស និងខ្សែសង្វាក់ផ្គត់ផ្គង់ផលិតកម្មនៅលើពិភពលោក

## មាតិកា


| | | *កថាខណ្ឌ* | *ទំព័រ* |
|---|---|---|---|
| I. | សេចក្តីផ្តើម | 1–3 | 6 |
| II. | ទិដ្ឋភាពទូទៅនៃកិច្ចពិភាក្សា | 4–21 | 7 |
| | ក. វគ្គទី១: ការជួញដូរមនុស្ស និងខ្សែសង្វាក់ផ្គត់ផ្គង់ផលិតកម្មនៅលើពិភពលោក: ការយល់ដឹងទៅលើបញ្ហាប្រឈម និងហានិភ័យរបស់អ្នកធុរកិច្ច និងកម្មករ | 7–8 | 8 |
| | ខ. វគ្គទី២: ការបង្កើតល្បែងទី១: ការឆ្លើយតបរបស់ផ្នែកធុរកិច្ចទៅលើហានិភ័យនៃការជួញដូរមនុស្ស | 9–10 | 9 |
| | គ. វគ្គទី៣: ការបង្កើតល្បែងទី២: ការឆ្លើយតបរបស់ផ្នែកធុរកិច្ចទៅលើហានិភ័យនៃការជួញដូរមនុស្ស: ទស្សនៈស្តីពីការជ្រើសរើសបុគ្គលិកប្រកបដោយក្រមសីលធម៌ | 11–13 | 10 |
| | ឃ. វគ្គទី៤: ការបង្កើតល្បែងទី៣: ភាពជាដៃគូ និងកិច្ចសន្ទនានៅក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស | 14–15 | 12 |
| | ង. វគ្គទី៥: បទដ្ឋានអន្តរជាតិ និងគោលនយោបាយសាធារណៈសម្រាប់ដោះស្រាយបញ្ហាជួញដូរមនុស្ស និងខ្សែសង្វាក់ផ្គត់ផ្គង់ | 16–17 | 14 |
| | ច. វគ្គទី៦: យុទ្ធសាស្ត្រថ្មីសម្រាប់ខ្សែសង្វាក់ផ្គត់ផ្គង់ និងការចូលរួមរបស់អ្នកប្រើប្រាស់ | 18–19 | 15 |
| | ឆ. វគ្គទី៧: តើយើងនឹងធ្វើដំណើរចាកចេញពីចំណុចនេះទៅទីណា? ជំហានបន្ទាប់សម្រាប់ការចូលរួមរបស់ខ្សែសង្វាក់ផ្គត់ផ្គង់ផលិតកម្ម | 20–21 | 16 |

អត្ថបទបន្ថែម

I. វង្វាស់មូលដ្ឋាន និងសូចនាករសម្រាប់ធានាឲ្យខ្សែ
សង្វាក់ផ្គត់ផ្គង់ផលិតកម្មចៀសផុតពីអំពើជួញដូរមនុស្ស ........................................................................... 18
II. របៀបវារៈនៃកិច្ចពិគ្រោះយោបល់របស់អ្នកជំនាញ ស្តីពីការជួញដូរមនុស្ស និង
ខ្សែសង្វាក់ផ្គត់ផ្គង់ផលិតកម្មនៅលើពិភពលោក........................................................................................ 23

# I. សេចក្តីផ្តើម

1. នៅថ្ងៃទី១២ និងទី១៣ ខែវិច្ឆិកា ឆ្នាំ២០១២ អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសលើស្ត្រី និងកុមារ បានមកចូលរួមប្រជុំកិច្ចពិគ្រោះយោបល់អន្តរជាតិនៅទីក្រុងអង់ការ៉ាស្តីពីការជួញដូរមនុស្ស និងខ្សែសង្វាក់ផ្គត់ផ្គង់នៅលើពិភពលោក[1]។ កិច្ចពិគ្រោះយោបល់នេះមានការចូលរួមពីអ្នកជំនាញការសំខាន់ៗ និងស្ថាប័នប្រឆាំងការជួញដូរនានារួមទាំងអ្នកតំណាងចំនួន២០រូបមកពីសហគមន៍ធុរកិច្ច សហជីពការងារ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នបណ្ឌិតសភា និងអង្គការអន្តរជាតិនានា។ គោលបំណងនៃកិច្ចប្រជុំនេះគឺ៖

ក. ដើម្បីពិភាក្សាពីរបកគំហើញ និងអនុសាសន៍សំខាន់ៗរបស់អ្នករាយការណ៍ពិសេស ដែលបានព្រាងនៅក្នុងរបាយការណ៍របស់លោកស្រី និងដាក់ជូនទៅមហាសន្និបាត[2]។

ខ. ដើម្បីបង្កើន និងពង្រីកនូវជំនាញផ្នែកការជួញដូរមនុស្ស និងខ្សែសង្វាក់ផ្គត់ផ្គង់។

គ. ដើម្បីចែករំលែកព័ត៌មានក្នុងចំណោមភាគីពាក់ព័ន្ធចំពោះនិន្នាការបច្ចុប្បន្ន ការអនុវត្តន៍ល្អៗ និងមេរៀនដែលបានរៀនសូត្រ ដោយរួមបញ្ចូលទាំងករណីសិក្សាសម្រាប់ដោះស្រាយការជួញដូរមនុស្សនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សាកល។

ឃ. ដើម្បីពិចារណា និងពិភាក្សាលើផ្នែកផ្សេងៗទាក់ទងនឹងបទដ្ឋាន និងសូចនាករសម្រាប់ខ្សែសង្វាក់ផ្គត់ផ្គង់ដែលចៀសផុតពីការជួញដូរមនុស្ស។

2. គំនិតផ្តួចផ្តើមរបស់អ្នករាយការណ៍ពិសេសត្រូវបានទទួលសាទរពីសំណាក់សិក្ខាកាម ដែលយល់ស្របថា កិច្ចខិតខំប្រឹងប្រែងឱ្យបានខ្លាំងក្លាដើម្បីប្រឆាំងការជួញដូរមនុស្សនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់គឺជាការងារសំខាន់ និងធ្វើឡើងបានចំពេលវេលាល្អ។

3. របាយការណ៍ថ្មីនេះសង្ខេបពីកិច្ចពិភាក្សា ដែលបានធ្វើឡើងនៅក្នុងកិច្ចប្រជុំ។ ឯកសារពាក់ព័ន្ធទាំងអស់គឺអាចរកបាននៅលើគេហទំព័ររបស់អ្នករាយការណ៍ពិសេស៖ www.ohchr.org/EN/Issues/Trafficking/Pages/GlobalSupplyChains.aspx.

[1] ការរៀបចំនៃកិច្ចពិគ្រោះយោបល់ត្រូវបានក្រុមការងារនៃអង្គការសហប្រជាជាតិប្រចាំនៅប្រទេសទួរគី ជាពិសេសការិយាល័យអ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅប្រទេសនេះសម្របសម្រួលបានយ៉ាងល្អ ហើយអ្នករាយការណ៍ពិសេសសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការិយាល័យនេះ។

[2] A/67/261

# II. ទិដ្ឋភាពទូទៅនៃកិច្ចពិភាក្សា

4. កិច្ចពិគ្រោះយោបល់នេះត្រូវបានបើកជាផ្លូវការដោយអ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅប្រទេសទួរគី ដែលបានស្វាគមន៍ចំពោះសិក្ខាកាមទាំងអស់ និងបង្ហាញពីអំណរសម្រាប់ឱកាសទទួលកិច្ចប្រជុំនេះ និងបានផ្តល់នូវទិដ្ឋភាពទូទៅនៃការជួញដូរមនុស្សនៅក្នុងបរិបទសាកលោក និងតំបន់។ លោកបានលើកទឹកចិត្តដល់សិក្ខាកាមឲ្យចែករំលែកអនុសាសន៍នៅក្នុងកិច្ចប្រជុំជាមួយការិយាល័យរបស់លោក និងដល់ប្រទេសទួរគីដែលជាកន្លែងពិសោធន៍សម្រាប់ធ្វើការសាកល្បង និងធ្វើឲ្យអនុសាសន៍ទាំងនោះមានតម្លៃនៅពេលអនាគត។

5. អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសលើស្ត្រី និងកុមារ លោកស្រី ចយ ង៉ូហ្ស៊ី អេហ្សេឡូ បានបន្តថ្លែងសុន្ទរកថាបើក។ លោកស្រីបានស្វាគមន៍ចំពោះសិក្ខាកាមទាំងអស់ និងពិនិត្យឡើងវិញលើទម្រង់ និងដំណើរការនៃកិច្ចពិគ្រោះយោបល់។ អ្នករាយការណ៍ពិសេសបានបញ្ជាក់ពីគោលបំណងនៃកិច្ចប្រជុំ រួមទាំងគោលបំណងស្វែងរកវិធីលើកកម្ពស់ភាពជាដៃគូឯកជន-សាធារណៈ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ត្រួតពិនិត្យនិងរៀនសូត្រពីគ្នាទៅវិញទៅមក និងគំនិតផ្តួចផ្តើមដែលមានស្រាប់ ហើយនិងចែករំលែកព័ត៌មាន និងពិចារណាលើតម្រូវការ និងការបង្កើតឧបករណ៍ និងរង្វាស់មូលដ្ឋានថ្មីៗទាក់ទងនឹងផ្នែកធុរកិច្ចក្នុងគោលបំណងដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ឲ្យមានប្រសិទ្ធភាព។ (សូមមើលអត្ថបទបន្ថែមទី១)

6. របៀបវារៈនៃកិច្ចពិគ្រោះយោបល់ត្រូវបានបែកចែកជា៧ប្រធានបទ និងជាវគ្គផ្សេងៗ ដែលបានធ្វើឡើងក្នុងរយៈពេលជាងពីរថ្ងៃ (សូមមើលអត្ថបទបន្ថែមទី២)។ ប្រធានបទទាំងនេះមានដូចតទៅ៖

1. បញ្ហាប្រឈម និងហានិភ័យ ដែលបណ្តាលមកពីអំពើជួញដូរមនុស្ស និងដែលប៉ះពាល់ដល់

   កម្មករ និងផ្នែកធុរកិច្ច។

2. ការឆ្លើយតបរបស់ផ្នែកធុរកិច្ចចំពោះការជួញដូរមនុស្ស។

3. ទស្សនៈនៃការជ្រើសរើសបុគ្គលិកប្រកបដោយក្រមសីលធម៌ និងតួនាទីរបស់ទីភ្នាក់ងារជ្រើសរើសឯកជន។

4. មធ្យោបាយនៃភាពជាដៃគូចំពោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

5. បទដ្ឋានអន្តរជាតិ និងគោលនយោបាយសាធារណៈសម្រាប់ដោះស្រាយការជួញដូរមនុស្ស ពលកម្មដោយបង្ខំ នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់។

6. យុទ្ធសាស្ត្រថ្មីៗសម្រាប់ការចូលរួមរបស់ខ្សែសង្វាក់ផ្គត់ផ្គង់ និងអ្នកប្រើប្រាស់។

7. ជំហានបន្ទាប់ដែលត្រូវចាត់វិធានការបន្ត។

ប្រធានបទខាងលើត្រូវបានពិភាក្សាដោយយោងទៅលើឯកសារសាវតា ដែលរៀបចំឡើងសម្រាប់កិច្ចពិគ្រោះយោបល់នេះ[3]។

## ក. វគ្គ១: អំពើជួញដូរមនុស្ស និងខ្សែសង្វាក់ផ្គត់ផ្គង់នៅលើពិភពលោក: ការយល់ដឹងពីបញ្ហាប្រឈម និងហានិភ័យសម្រាប់ផ្នែកធុរកិច្ច និងពលករ

7. តាមរយៈបទបង្ហាញ វាគ្មិនបានផ្តោតអារម្មណ៍លើការយល់ដឹងពីទំនាក់ទំនងរវាងការជួញដូរមនុស្ស និងខ្សែសង្វាក់ផ្គត់ផ្គង់សាកល និងគ្រោះថ្នាក់ ដែលកម្មករ និងធុរកិច្ចកំពុងប្រឈម។ គោលបំណងនៅក្នុងវគ្គនេះគឺត្រូវកំណត់ថាតើ យ៉ាងម៉េច ហេតុអ្វីនិងទីកន្លែងណា ដែលការជួញដូរមនុស្សបង្ហាញឲ្យឃើញនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ និងដើម្បីកាន់តែយល់ដឹងឲ្យច្បាស់ថែមទៀតពីឱកាស និងបញ្ហាប្រឈម ដែលផ្នែកធុរកិច្ចត្រូវដោះស្រាយ។

8. វាគ្មិនបានផ្តោតលើប្រធានបទផ្សេងៗដើម្បីពិភាក្សាបរិបទជុំវិញការចូលរួមរបស់ផ្នែកធុរកិច្ច។ ប្រធានបទទាំងនេះរួមបញ្ចូលទាំងក្របខ័ណ្ឌទេសន្តប្រវេសន៍អន្តរជាតិ ករណីជាក់ស្តែងនៃការរំលោភបំពាន ដែលប្រព័ន្ធផ្សព្វផ្សាយបានចងក្រង ទម្រង់ផ្សេងៗនៃការកេងប្រវ័ញ្ចនៅក្នុងដំណាក់កាលជ្រើសរើសនិងបម្រើការងារនៅក្នុងរយៈពេលមានទំនាក់ទំនងការងារ ហើយនិងកត្តានានា ដែលបង្កើនភាពងាយរងគ្រោះរបស់ពលករទេសន្តរប្រវេសន៍។ វាគ្មិនចំនួន៥រូបបានពោលសំដៅដល់ប្រភេទពិតប្រាកដនៃអំពើជួញដូរមនុស្សដែលប្រព្រឹត្តឡើងក្នុងរូបភាពជាបណ្តាញសាកល ដោយលើកយកករណីនៅអាស៊ី អាហ្វ្រិក អឺរ៉ុប និងចក្រភពអង់គ្លេស រួមបញ្ចូលទាំងវិស័យសេដ្ឋកិច្ចដូចជាផលិតកម្ម កសិកម្ម និងសេវាកម្មជាដើម។ លក្ខណៈស្របគ្នាមួយ ដែលវាគ្មិននានាបានលើកឡើងគឺការជំពាក់បំណុល ដែលពលករទេសន្តរប្រវេសន៍កំពុងប្រឈម និងជាញឹកញាប់ត្រូវបង់ក្នុងចំនួនហួសប្រមាណ សូម្បីតែតម្លៃការជ្រើសរើសខុសច្បាប់ និងតម្លៃ

[3] អាចរកបាននៅគេហទំព័រ www.ohchr.org/Documents/Issues/Trafficking/Consultation/2012/BackgroundPaper.pdf

ផ្សេងៗទៀតនៅដំណាក់កាលផ្សេងៗនៃដំណើរការទេសន្តប្រវេសន៍។ ពលករត្រូវបង់នៅគ្រប់ដំណាក់កាលទាំងអស់ ដែលបណ្តាលឲ្យភាពងាយរងគ្រោះចំពោះការរំលោភបំពាន និងការកេងប្រវ័ញ្ចកាន់តែកើនឡើងនៅក្នុងប្រទេសដែលពួកគេទៅធ្វើការ និងនៅហ្នឹងកន្លែងការងារ។ លក្ខណៈសំខាន់ផ្សេងទៀត ដែលវាគ្មិន និងសិក្ខាកាមបានលើកឡើងគឺ ការរួមបញ្ចូលភាពងាយរងគ្រោះរបស់ពលករក្រីក្រដែលមិនមានជំនាញ ហានិភ័យដែលមានក្នុងសេដ្ឋកិច្ចក្រៅផ្លូវការ បញ្ហាទាំងឡាយពាក់ព័ន្ធនឹងប្រព័ន្ធទេសន្តប្រវេសន៍ដែលមិនត្រូវបានរៀបចំត្រឹមត្រូវ ឬខ្វះខាតការរៀបចំត្រឹមត្រូវ បញ្ហាប្រឈមចំពោះធុរកិច្ចនៅក្នុងផ្នែកលក់រាយ និងផ្នែកបដិសណ្ឋារកិច្ច (ជាពិសេសទាក់ទងនឹងលក្ខខណ្ឌការងារនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់កសិកម្ម និងទម្រង់នៃការរំលោភបំពានជាក់ស្តែងដូចជា ការរឹបអូសយកលិខិតឆ្លងដែន ការកេងប្រវ័ញ្ចនៅក្នុងដំណើរការជ្រើសរើស ការកំណត់ចំណែកប្រាក់សន្តិសុខទុកសម្រាប់"ធានាមិនឲ្យមានការរត់ចេញ" និងការគំរាមកំហែងរំលោភបំពានផ្នែករាងកាយ ឬផ្នែកផ្លូវចិត្តជាដើម។ សិក្ខាកាមក៏បានកត់សម្គាល់លើតួនាទីដ៏សំខាន់ ដែលផ្នែកធុរកិច្ចអាចធ្វើដើម្បីដោះស្រាយលក្ខខណ្ឌការជ្រើសរើស និងបម្រើការងារនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ អានុភាពដ៏ធំ ដែលអ្នកទិញមានចំពោះអ្នកផ្គត់ផ្គង់ថ្នាក់ទីមួយរបស់ពួកគេ សក្តានុពលសម្រាប់ពង្រឹងនៅក្នុងការធ្វើសវនកម្ម និងការត្រួតពិនិត្យលើបទដ្ឋានការងារ និងសិទ្ធមនុស្ស និងសក្តានុពលសម្រាប់ធុរកិច្ច ដើម្បីជំរុញឲ្យមានការបញ្ចេញមតិកាន់តែច្រើនពីសំណាក់ពលករ និងដើម្បីធានាឲ្យមានសំណងការខូចខាតនៅក្នុងកន្លែងការងារ និងសហគមន៍ដែលពួកគេធ្វើការ។ សិក្ខាកាមក៏សង្កត់ធ្ងន់លើតួនាទីដ៏សំខាន់របស់រដ្ឋាភិបាល និងអាជ្ញធរទទួលបន្ទុកវិស័យការងារចំពោះការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងតម្រូវឲ្យបង្កើនធនធាន និងសមត្ថភាពរបស់ក្រុមអធិការកិច្ចការងារ ដើម្បីដោះស្រាយបញ្ហាផងដែរ។

## ខ. វគ្គ២: ការបង្កើតល្បែងទី១: ការឆ្លើយតបរបស់ធុរកិច្ចចំពោះគ្រោះថ្នាក់នៃការជួញដូរមនុស្ស

9. វាគ្មិនបានពិភាក្សាលើការឆ្លើយតបរបស់សហគ្រាសចំពោះគ្រោះថ្នាក់នៃការជួញដូរមនុស្សនៅក្នុងចង្វាក់ផ្គត់ផ្គង់។ គោលបំណងនៃវគ្គនេះគឺដើម្បីស្រាវជ្រាវរកវិធីផ្សេងៗដែលក្រុមហ៊ុនដោះស្រាយភាពប្រយុយប្រថាននេះ ដោយលើកយកឧទាហរណ៍ជាក់

ស្តែងពីវិស័យឧស្សាហកម្ម ដែលបានជ្រើសរើស និងដើម្បីរៀបចំជាមេរៀនសម្រាប់ការផ្តួចផ្តើមគំនិតប្រឆាំងការជួញដូរ ដែលដឹកនាំដោយផ្នែកធុរកិច្ចប្រកបដោយប្រសិទ្ធភាព។

10. កិច្ចពិភាក្សាទាំងឡាយ ដែលបានប្រារព្ធធ្វើនៅអំឡុងពេលនេះផ្តោតលើការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុនចំនួនពីរ និងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេដើម្បីត្រួតពិនិត្យលើចង្វាក់ផ្គត់ផ្គង់របស់ពួកគេប្រកបដោយប្រសិទ្ធភាព និងដើម្បីកាត់បន្ថយគ្រោះថ្នាក់ទាក់ទងការជួញដូរ។ អង្គការសម្ព័ន្ធភាពពលរដ្ឋចម្រុះសម្រាប់ឧស្សាហកម្មអេឡិចត្រូនិច[4] ត្រូវបានកំណត់ធ្វើជាគំរូសម្រាប់ការអនុវត្តដ៏ល្អមួយនៅក្នុងវិស័យឧស្សាកម្ម ដោយបានរួបរួមក្រុមហ៊ុនតូចធំមកពីគ្រប់វិស័យ ដើម្បីលើកកម្ពស់បទដ្ឋានទាក់ទងនឹងខ្សែសង្វាក់ផ្គត់ផ្គង់សម្រាប់ការងារ បរិស្ថាន សីលធម៌ សុខភាព និងសុវត្ថិភាព។ ប្រធានបទផ្សេងទៀតត្រូវបានពិភាក្សាក្នុងវគ្គនេះរួមមានតួនាទីនៃការវាយតម្លៃសវនកម្មសង្គម និងកន្លែងការងារ លក្ខខណ្ឌជ្រើសរើស និងបម្រើការងារសម្រាប់ពលករនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ សារៈសំខាន់នៃការធ្វើការរួមគ្នាជាមួយអ្នកផ្គត់ផ្គង់ (ឧទាហរណ៍៖ តាមរយៈការលើកកម្ពស់កម្មវិធីបណ្តុះបណ្តាល និងកសាងសមត្ថភាព) តម្រូវការសម្រាប់គំនិតផ្តួចផ្តើមទំនួលខុសត្រូវផ្នែកសង្គម ដើម្បីផ្តោតលើការយកចិត្តទុកដាក់ចំពោះអ្នកផ្តល់សេវាកម្ម (ឧទាហរណ៍៖ ការិយាល័យទទួលទូរស័ព្ទហៅចូល) និងសារៈសំខាន់នៃការផ្តល់ការពិចារណាពិសេសលើសិទ្ធិរបស់ពលករចំណាកស្រុក និងបរទេស ដែលជាប់កិច្ចសន្យានៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់។ វាគ្មិនក៏បានលើកឡើងពីសារៈសំខាន់នៃការសន្ទនាគ្នារវាងសហគមន៍ធុរកិច្ច ក្រុមសង្គមស៊ីវិល និងប្រព័ន្ធរបស់អង្គការសហប្រជាជាតិ ដើម្បីលើកកម្ពស់ភាពជាដៃគូនៅក្នុងវិស័យឯកជន-សាធារណៈ ឧទាហរណ៍ដូចជា ភាពជាដៃគូដែលបង្ហាញថា ក្រុមហ៊ុនក៏អាចចូលរួមនៅក្នុងការផ្តួចផ្តើមគំនិតប្រឆាំងការជួញដូរខាងក្រៅកម្មវិធីទំនួលខុសត្រូវសង្គមសម្រាប់សាជីវកម្មនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់ពួកគេ។ វាគ្មិនក៏បានបង្ហាញឲ្យស្គាល់ពីសម្ព័ន្ធធុរកិច្ចសាកលប្រឆាំងការជួញដូរមនុស្សដែលជាគំនិតផ្តួចផ្តើមថ្មីមួយ (www.gbcat.org/) ចាប់ផ្តើមនៅឆ្នាំ២០១២។ គំនិតផ្តួចផ្តើមនេះត្រូវបានបង្កើតដោយក្រុមហ៊ុនផ្សេងៗ ដែលមានគំនិតដូចគ្នា ជាទីកន្លែងដែលធុរកិច្ចទាំងឡាយអាចមកជួបជុំគ្នា ដើម្បីពិភាក្សាពីកិច្ចខិតខំប្រឹងប្រែងប្រឆាំងការជួញដូរ និងការរៀនសូត្រពីគ្នាទៅវិញទៅមក។

[4] See www.eicc.info/.

## គ. វគ្គ៣: ការបង្កើតល្បែង២: ការឆ្លើយតបផ្នែកធុរកិច្ចចំពោះគ្រោះថ្នាក់នៃការជួញដូរមនុស្ស: ទស្សនៈនៃការជ្រើសរើសបុគ្គលិកប្រកបដោយក្រមសីលធម៌

11. សិក្ខាកាមនៅក្នុងវគ្គនេះបានអធិប្បាយពីវគ្គ២ និងពិចារណាលើទស្សនៈនៃការជ្រើសរើសប្រកបដោយសីលធម៌ ដែលជាចំណាត់ការបង្ហាញឲ្យឃើញនៅក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ គោលបំណងនៃវគ្គនេះគឺត្រូវកំណត់ពីការឆ្លើយតបនៃឧស្សាហកម្មជ្រើសរើសចំពោះបញ្ហា ដើម្បីត្រួតពិនិត្យមើលតួនាទី ដែលសមាគមឧស្សាហកម្ម និងជំនួញបានធ្វើ និងដើម្បីណែនាំពីការយល់ដឹង និងឧបករណ៍ជាក់ស្តែងសម្រាប់ប្រើប្រាស់ក្នុងការជ្រើសរើស និងបម្រើការងារប្រកបដោយក្រមសីលធម៌។

12. វាគ្មិនបានលើកឡើងពីសារៈសំខាន់នៃក្រមសីលធម៌ ដែលអនុម័តដោយសហព័ន្ធអន្តរជាតិនៃទីភ្នាក់ងារមុខរបរឯកជន ដែលអាចប្រើប្រាស់ជាឯកសារយោងដ៏សំខាន់សម្រាប់កិច្ចប្រឹងប្រែងរបស់ផ្នែកឧស្សាហកម្ម ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងដើម្បីលើកកម្ពស់ការជ្រើសរើសប្រកបដោយសីលធម៌។ តួនាទីរបស់សហព័ន្ធក៏បានសង្កត់បញ្ជាក់ជាពិសេសលើកិច្ចខិតខំប្រែងរបស់ខ្លួន ដើម្បីជំរុញឱ្យមានការផ្តល់សច្ចាប័នលើអនុសញ្ញាលេខ១៨១ របស់អង្គការពលកម្មអន្តរជាតិ ស្តីពីទីភ្នាក់ងារមុខរបរឯកជន ដែលជាជំហានដំបូងនៅក្នុងការបង្កើតមូលនិធិស្របច្បាប់ និងផ្លូវការសម្រាប់ឧស្សាហកម្មជ្រើសរើសនៅកម្រិតថ្នាក់ជាតិ។ វាគ្មិនបានសង្កត់បញ្ជាក់លើសារៈសំខាន់នៃសហគមន៍ធុរកិច្ច ដែលធ្វើការងារជាមួយក្រុមសង្គមស៊ីវិល និងពិគ្រោះយោបល់ជាមួយសហជីព ដោយជំរុញឲ្យរដ្ឋាភិបាលផ្តល់សច្ចាប័នលើអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិ និងដើម្បីបង្កើតយន្តការ ដែលតម្រូវឲ្យមានការទប់ស្កាត់ទីភ្នាក់ងារជ្រើសរើសដែលមិនស្មោះត្រង់ មិនឲ្យទាមទារតម្លៃហួសប្រមាណសម្រាប់សេវាកម្មនានាពីពលករ។

13. វាគ្មិនដទៃទៀតបានលើកឡើងពីគំរូដ៏សំខាន់មួយនៃការជ្រើសរើសប្រកបដោយសីលធម៌ ផលប្រយោជន៍ធុរកិច្ចបានមកពីគំរូនោះ ភាពប្រឈមមួយចំនួននៅក្នុងការអនុវត្តន៍ និងចំណាត់ការ ដែលជួយលុបបំបាត់ហានិភ័យនៃការជួញដូរដល់ពលករ។ ឧបករណ៍ថ្មី និងបង្កើតចេញ ដែលលើកកម្ពស់ការជ្រើសរើសប្រកបដោយសីលធម៌ និងទេសន្តប្រវេសន៍ប្រកបដោយសុវត្ថិភាពក៏ត្រូវបានបង្ហាញឲ្យឃើញ រួមទាំងគោលការណ៍ទីក្រុងដាកាស្តីពីការធ្វើទេសន្តប្រវេសន៍ប្រកបដោយភាពថ្លៃថ្នូរ[5] ដែលត្រូវបាន

[5] មើល www.dhaka-principles.org/.

បង្កើតឡើងដោយវិទ្យាស្ថានសិទ្ធមនុស្ស និងធុរកិច្ច មានមូលដ្ឋាននៅចក្រភពអង់គ្លេស។ គោលការណ៍ដាកាគឺផ្អែកលើគោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស និងបទដ្ឋានពលកម្ម និងសិទ្ធិមនុស្សអន្តរជាតិ។ ឧបករណ៍ទាំនេះផ្តល់គោលការណ៍ ដ៏សំខាន់ ដែលនយោជក និងអ្នកជ្រើសរើសពលករទេសន្តរប្រវេសន៍គួរគោរពនៅក្នុង ដំណាក់កាលនីមួយៗនៃដំណើរការជ្រើសរើស ការបម្រើការងារ និងការធ្វើមាតុភូមិនិវត្តន៍ ដើម្បីធានាឲ្យមានការធ្វើទេសន្តប្រវេសន៍ប្រកបដោយភាពថ្លៃថ្នូរ។ ឧបករណ៍ដទៃទៀតដែលបានបង្ហាញនៅក្នុងវគ្គនេះគឺជាឧបករណ៍ទាំងឡាយ ដែលបានបង្កើតឡើងថ្មីៗដោយអង្គការ«តថភាព»(វេរីតេ) ដែលជាអង្គការមិនមែនរដ្ឋាភិបាលមួយមានមូលដ្ឋាននៅសហរដ្ឋអាមេរិច

រួមទាំងឯកសារណែនាំសម្រាប់ការចាត់ចែងឱ្យចូលបម្រើការងារសមរម្យ[6] និងគោលការណ៍សីលធម៌ដើម្បីការជ្រើសរើសកម្លាំងពលកម្មឆ្លងដែន[7]។ ឧបករណ៍ទាំងនេះផ្តល់នូវគោលការណ៍បំពេញបន្ថែម និងជាក្របខ័ណ្ឌទូទៅនៃគោលការណ៍និយាម និងបច្ចេកទេសសម្រាប់ផ្នែកធុរកិច្ចកគ្រប់កម្រិតទាំងអស់ដែលចូលរួមក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ដោយរាប់ចាប់ពីសាជីវកម្មពហុជាតិដែលមានពាណិជ្ជសញ្ញាធំៗ និងទីភ្នាក់ងារផ្គត់ផ្គង់ផលិតកម្មរបស់ពួកគេ រហូតដល់ទីភ្នាក់ងារជ្រើសរើសឯកជនដែលចូលរួមនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សាកលទាំងនោះ។

## ឃ. វគ្គ៤: ការបង្កើតល្បែង៣: ភាពជាដៃគូ និងកិច្ចសន្ទនានៅក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

14. សិក្ខាកាមបានស្រាវជ្រាវរកមូលបទនៃភាពជាដៃគូ និងការសន្ទនា ដែលជាកត្តាដ៏សំខាន់នៅក្នុងការដោះស្រាយគ្រោះថ្នាក់នៃការជួញដូរមនុស្សនៅក្នុងចង្វាក់ផ្គត់ផ្គង់។ គោលបំណងនៃវគ្គនេះគឺត្រូវបង្ហាញឲ្យឃើញ និងវាយតម្លៃលើគំរូនៃការអនុវត្តន៍ដ៏ល្អនៅក្នុងការចូលរួមរបស់ពហុភាគីជាប់ពាក់ព័ន្ធ និងកិច្ចសន្ទនាសង្គម។

15. វាគ្មិនបានទាញចំណាប់អារម្មណ៍ដល់អង្គការ និងក្រុមហ៊ុនមួយចំនួន ដែលធ្វើការជាមួយគ្នានៅក្នុងភាពជាដៃគូ។ ស្ថាប័នទាំងនោះរួមមាន សមាគម«បញ្ឈប់អំពើជួញដូរមនុស្សនាពេលឥឡូវនេះ» ដែលជាសមាគមមួយបង្កើតនៅក្នុងឆ្នាំ២០០៦ នៅ ប្រទេសស្វីស ដែលលើកកម្ពស់ដល់គោលការណ៍ក្រមសីលធម៌ក្រុងអាតែន[8]។ សមាគមនេះស្វះស្វែងដើម្បីលើកកម្ពស់ចំណេះដឹងនៃការជួញដូរមនុស្ស និងតួនាទី ដែលធុរកិច្ចអាច

[6] មើល www.verite.org/helpwanted/toolkit.
[7] មើល www.verite.org/sites/default/files/ethical_framework_paper_20120209_PRINTED.pdf.
[8] មើលwww.endhumantraffickingnow.com/.

ធ្វើដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស តាមរយៈការធ្វើជាដៃគូនិងភាគីហត្ថលេខីលើគោលការណ៍ក្រមសីលធម៌ក្រុងអាតែន និងអង្គការដទៃទៀតដើម្បីបង្កើតឧបករណ៍ទាំងឡាយដូចជា វគ្គសិក្សាតាមប្រព័ន្ធអិនធើណេត (ដោយរួមសហការជាមួយ«គំនិតផ្តួចផ្តើមសាកលដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស») និងករណីសិក្សាដើម្បីលើកកម្ពស់ការអនុវត្តន៍ដ៏ល្អ (ជាមួយនឹងអង្គការ«កតិកាសញ្ញាសាកល»)។ សមាគមនេះក៏ធ្វើជាមួយប្រព័ន្ធផ្សព្វផ្សាយសាកល ដើម្បីលើកកម្ពស់ចំណេះដឹងសាធារណៈផងដែរ។ សិក្ខាកាមនៅក្នុងវគ្គនេះក៏ពិចារណាលើសកម្មភាពនៃគម្រោងអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិប្រឆាំងអំពើជួញដូរមនុស្ស[9] ដែលបានធ្វើការជាមួយប្រព័ន្ធផ្សព្វផ្សាយ និងក្រុមអ្នកសារព័ត៌មានផ្នែកស៊ើបអង្កេតដូចជា កម្មវិធីដើម្បីសេរីភាពរបស់បណ្តាញទូរទស្សន៍ស៊ីអិនអិន ដើម្បីលើកឡើងពីការរំលោភបំពាននៃការជួញដូរមនុស្សនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ គម្រោងនេះបានធ្វើការជាមួយក្រុមហ៊ុនបច្ចេកទេសព័ត៌មានផងដែរ ដើម្បីសម្របសម្រួលដល់ការបង្កើតការដាក់ជូនព័ត៌មានតាមបណ្តាញទូរស័ព្ទបច្ចេកវិទ្យាដល់មន្ត្រីអនុវត្តជំនួយផ្នែកច្បាប់ដើម្បីធ្វើការកំណត់អត្តសញ្ញាណជនរងគ្រោះដោយសារអំពើជួញដូរ ដោយផ្តល់សមត្ថកិច្ចស្នូលនៃក្រុមហ៊ុនខណៈពេលជួយក្នុងការអនុវត្តច្បាប់ឲ្យកាន់តែមានប្រសិទ្ធភាព។ ជាចុងក្រោយ សិក្ខាកាមក៏បានលើកឡើងពីការធ្វើយុទ្ធនាការមិនសម្រាប់លក់នៅក្នុងសហរដ្ឋអាមេរិច និងការងារនៃភាពជាដៃគូរបស់ខ្លួនជាមួយមូនិធិសិទ្ធិការងារអន្តរជាតិ ដើម្បីផ្តល់ឲ្យអ្នកប្រើប្រាស់នូវព័ត៌មានអំពីទំនាក់ទំនងរវាងពលកម្មដោយបង្ខំ អំពើជួញដូរមនុស្ស និងផលិតផលសម្រាប់ប្រើប្រាស់ ដើម្បីអាចឲ្យពួកគេអនុវត្តបានកាន់តែប្រសើរ ជម្រើសទទួលព័ត៌មានកាន់តែច្រើនពីការជាវទិញរបស់ពួកគេ[10]។ ការផ្តួចផ្តើមគំនិតដ៏សំខាន់មួយក្នុងចំណោមការផ្តួចផ្តើមគំនិតសំខាន់ដទៃទៀតនៃយុទ្ធនាការមិនសម្រាប់លក់គឺជាគេហទំព័រ និងការដាក់ជូនព័ត៌មានតាមប្រព័ន្ធទូរស័ព្ទបច្ចេកវិទ្យាប្រ៊ីធូរើក ដែលអនុញ្ញាតឲ្យអ្នកប្រើប្រាស់ ដែលចូលទៅកាន់គេហទំព័រ ឬស្កែនបាកូដផលិតផលជាមួយការអនុវត្តន៍ ដើម្បីទទួលបានព័ត៌មានពិស្តារអំពីការផ្តួចផ្តើមគំនិតរបស់ក្រុមហ៊ុនដើម្បីដោះស្រាយទាសភាពសម័យទំនើប។ គេហទំព័រនេះផ្តល់កម្រិតថ្នាក់ពី"អេ" ដល់ "អេហ្វ" ចំពោះស្លាកសញ្ញានីមួយៗ។ កិច្ចពិភាក្សនេះបានសរុបដោយមានការពិចារណាលើតួនាទីនៃកិច្ចសន្ទនាសង្គមជាមួយគំរូនៃសហជីពកសិកម្មនៅក្នុងជោគជ័យលើសិទ្ធិ និងការការពារការចរចាដំឡើងប្រាក់បៀវត្សរ៍រួមនៅប្រទេសអៀរឡង់ ដើម្បីរ៉ាប់រងលើពលករចំណាកស្រុកនៅក្នុងវិស័យនេះ មជ្ឈមណ្ឌលសហជីពការងារជាតិនៅក្នុងប្រទេសនេប៉ាល់ និងកិច្ចខិតខំប្រឹងប្រែងរបស់

9 មើលwww.no-trafficking.org/.
10 មើល www.notforsalecampaign.org/.

ខ្លួនដើម្បីការពារព្រំដែនពលករចំណាកស្រុកនៅខាងក្រៅសម្រាប់តំបន់ឈូងសមុទ្រ និង ភាពជាដៃគូរវាងសហជីព និងសហគ្រាសនៅក្នុងប្រទេសឥណ្ឌា ដើម្បីធានាថា សិទ្ធិរបស់ពលករចំណាកស្រុកនៅក្នុងប្រទេសនោះត្រូវបានការពារ។

## ង. វគ្គ៥: បទដ្ឋានអន្តរជាតិ និងគោលនយោបាយសាធារណៈដោះស្រាយអំពើជួញដូរមនុស្ស និងខ្សែសង្វាក់ផ្គត់ផ្គង់

16. សិក្ខាកាមបានត្រួតពិនិត្យឡើងវិញលើបរិបទបទដ្ឋានអន្តរជាតិចំពោះការចូលរួមរបស់សហគមន៍ធុរកិច្ចប្រឆាំងការជួញដូរមនុស្សនៅក្នុងចង្វាក់ផ្គត់ផ្គង់សាកល។ គោលបំណងនៃវគ្គនេះគឺត្រូវដាក់ទីតាំងតួនាទីរបស់រដ្ឋាភិបាល និងទីភ្នាក់ងារអន្តររដ្ឋាភិបាលនៅក្នុងកិច្ចពិភាក្សានេះ ដើម្បីណែនាំពីគំរូនៃគោលនយោបាយសាធារណៈ ដែលដោះស្រាយនៅក្នុងចង្វាក់ផ្គត់ផ្គង់ និងការជួញដូរមនុស្ស និងដើម្បីទទួលបានការយល់ដឹងឲ្យកាន់តែប្រសើរពីអ្វី ដែលអ្នកអនុវត្តគោលនោបាយកំពុងអនុវត្តលើបញ្ហានេះ។

17. វាគ្មិនបានងបង្ហាញពីលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ ការងារ និងការប្រឆាំងអំពើជួញដូរមនុស្ស ដែលជាប់ពាក់ព័ន្ធ រួមមានពិធិសារដើម្បីរាំងទប់ស្កាត់ និងផ្តន្ទាទោសលើអំពើជួញដូរមនុស្ស ជាពិសេសលើស្ត្រី និងកុមារ ដោយបន្ថែមបង្គ្រប់លើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់រើសអើងប្រឆាំងនឹងស្ត្រីភេទ អនុសញ្ញាស្តិពីសិទ្ធិកុមារ និងពិធិសារជម្រើសស្តីពីការជួញដូរកុមារ ពេស្យាកម្មលើកុមារ និងអំពើអាសលើកុមារ សេចក្តីប្រកាសទីក្រុងវីយេន វេទិកាសកម្មភាពទីក្រុងប៉េកាំង និងគោលការណ៍ណែនាំរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សស្តីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស។ លិខិតុបករណ៍ចំនួនជាង២០ស្តីពីទាសភាព ការជួញដូរមនុស្ស និងពលកម្មដោយបង្ខំត្រូវបានទទួលស្គាល់ពីសិក្ខាកាម រួមទាំងអនុសញ្ញាលេខ ១៨៩ស្តីពីកម្មករបម្រើតាមផ្ទះរបស់អង្គការពលកម្មអន្តរជាតិ )។ កិច្ចពិភាក្សាក៏ផ្តោតលើតួនាទីរបស់រដ្ឋាភិបាលនៅក្នុងរដ្ឋបាលការងារ និងអធិការកិច្ចការងារផងដែរ លិខិតុបកណ៍បទដ្ឋាន និងផ្លូវការ (មួយចំនួនជាការព្រមព្រៀង) ដូចជា កិច្ចព្រមព្រៀងសាកល នីតិវិធីពិសេស និងការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស រួមទាំងតួនាទីរបស់ការិយាល័យនេះចំពោះការងាររបស់ស្ថាប័នអនុវត្តនានា និងតួនាទីរបស់រដ្ឋ ដែលជាអ្នកអនុវត្តភារកិច្ចចំបងនៅក្នុងវិស័យសិទ្ធិមនុស្ស។ ក្នុងពេលជាមួយគ្នានេះដែរ មានសំណួរមួយត្រូវបានលើកឡើងអំពីតម្រូវការសម្រាប់ការបំពេញ និងការអនុវត្តន៍លិខិតុបករណ៍អន្តរជាតិ និងច្បាប់ជាតិប្រកបដោយប្រសិទ្ធភាពសម្រាប់ភាគីរដ្ឋ តម្រូវការសម្រាប់ច្បាប់ថ្មី និងវិធានការនយោបាយដើម្បីដោះស្រាយចំពោះធុរកិច្ច និងចង្វាក់ផ្គត់ផ្គង់ដោយ

ផ្ទាល់ សារៈសំខាន់នៃការចូលរួមពីថ្នាក់តំបន់ និងអនុតំបន់ និងតួនាទីនៃភាពជាដៃគូ និងកិច្ចសហការនៅក្នុងបរិបទនេះ រួមទាំងតួនាទីដ៏សំខាន់របស់ក្រុមសង្គមស៊ីវិល។ ការពណ៌នាពិសេសក៏ត្រូវបានធ្វើលើគោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស ដែលត្រូវបានអនុវត្តថ្មីៗ និងត្រូវបានកំណត់ជាការកត់សម្គាល់លើការកើតឡើងនៃគោលនយោបាយថ្មី និងមិនជាប់កាតព្វកិច្ចច្បាប់សម្រាប់សាជីវកម្ម និងការចូលរួមរបស់ភាគីពាក់ព័ន្ធចម្រុះ។ គោលការណ៍ណែនាំនេះផ្តល់ជាបទដ្ឋាននិងបញ្ញត្តិរួម និងជាគោលការណ៍យោងសម្រាប់បន្ថយគ្រោះថ្នាក់នៃឥទ្ធិពលអវិជ្ជមានរបស់ផ្នែកធុរកិច្ចលើសិទ្ធិមនុស្ស។ យន្តការនីតិវិធីពិសេសមួយនៅក្នុងទម្រង់ក្រុមការងារក៏បានបង្កើតដោយក្រុមប្រឹក្សាសិទ្ធិមនុស្សដោយមានអាណត្តិ នៅក្នុងចំណោមយន្តការផ្សេងៗទៀត ដើម្បីលើកកម្ពស់ការផ្សព្វផ្សាយ និងការអនុវត្តន៍នៃគោលការណ៍នេះ។ ជាចុងក្រោយ យោបល់ជាច្រើនត្រូវបានបញ្ចេញចំពោះតម្រូវការទាក់ទងនឹងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដូចជា ធនាគារពិភពលោក សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងធនាគារអភិវឌ្ឍន៍ក្នុងតំបន់ និងតួនាទីនៃវេទិកាសាកលស្តីពីទេសន្តប្រវេសន៍ និងការអភិវឌ្ឍន៍នៅឆ្នាំខាងមុខ។

## ច. វគ្គ៦: យុទ្ធសាស្ត្រថ្មីសម្រាប់ខ្សែសង្វាក់ផ្គត់ផ្គង់ និងការចូលរួមពីសំណាក់អ្នកប្រើប្រាស់

18. កិច្ចពិភាក្សាទាំងឡាយ ដែលបានធ្វើនៅក្នុងវគ្គ៦នេះបានផ្តោតលើយុទ្ធសាស្ត្រសម្រាប់ការជាប់ទាក់ទងនៃខ្សែសង្វាក់ផ្គត់ផ្គង់ និងតួនាទីរបស់អ្នកប្រើប្រាស់នៅក្នុងវិស័យនេះ។ គោលបំណងនៃវគ្គនេះគឺត្រូវបង្ហាញពីឧបករណ៍បទដ្ឋាន និងឯកទេសសម្រាប់ធុរកិច្ច និងដំណោះស្រាយពឹងផ្អែកលើអ្នកប្រើប្រាស់ និងបច្ចេកវិទ្យាព័ត៌មានដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។

19. កម្មវិធីផ្តួចផ្តើមគំនិតមួយចំនួនត្រូវបានពិភាក្សាដោយសិក្ខាកាម។ កម្មវិធីទាំងនេះរួមមានយុទ្ធនាការទំនួលខុសត្រូវក្នុងការជាវទំនិញ ដែលធ្វើឡើងដោយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ(អាយអូអឹម)[11] និងស្វះស្វែងលើកកម្ពស់ចំណេះដឹងរបស់អ្នកប្រើប្រាស់អំពីផលិតផល ដែលពួកគេទិញ និងធ្វើឲ្យមានឥទ្ធិពលវិជ្ជមានលើឥរិយាបថរបស់អតិថិជន។ យុទ្ធនាការនេះមានបំណងលើកកម្ពស់ចំណេះដឹងជាប្រយោលនៅក្នុងចំណោមអ្នកធុរកិច្ច និងដើម្បីបង្កើតភាពជាដៃគូជាមួយសហគ្រាស ដូចជាទូរទស្សន៍អឹមធីវី និងសាអាឈី ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងដោះស្រាយការជួញដូរមនុស្ស។ អាយអូអឹមក៏ធ្វើការជាមួយទីភ្នាក់ងារការងារឯកជនផងដែរ។ ការផ្តួចផ្តើម

[11] មើល www.buyresponsibly.org/.

គំនិតថ្មី ដែលបានពិភាក្សានៅក្នុងវគ្គនេះគឺជាស្នាដៃរបស់«ស្នាមជើងនៃទាសភាព» និង«ផលិតកម្មនៅក្នុងវេទិកាលោកសេរី»[12]។ ការផ្តួចផ្តើមគំនិតនេះត្រូវបានចាប់ផ្តើមធ្វើនៅប្រាំឆ្នាំមុន ដោយមានគោលបំណងធ្វើឲ្យអ្នកប្រើប្រាស់ជាប់ពាក់ព័ន្ធផ្ទាល់នៅក្នុងបញ្ហាជួញដូរមនុស្ស និងការប្រើប្រាស់អំណាចនៃកិច្ចសន្ទនាដើម្បីជំរុញឲ្យមានការផ្លាស់ប្តូរឥរិយាបថ។ ស្នាមជើងនៃទាសភាពអនុញ្ញាតឲ្យអ្នកប្រើប្រាស់ស្ទង់មតិខ្លីៗតាមប្រព័ន្ធអ៊ិនធើណែត ដើម្បីរកឲ្យឃើញពីទំនាក់ទំនងនៃទាសភាពសម័យទំនើប ដោយណែនាំពួកគេពីសំណួរដំបូងសាមញ្ញ៖ "តើមានទាសករប៉ុន្មាននាក់ធ្វើការឲ្យអ្នក?"។ ផ្ទុយពីនេះ ផលិតកម្មនៅក្នុងវេទិកាលោកសេរីគឺអំពាវនាវដល់ក្រុមហ៊ុនឲ្យធ្វើការលុបបំបាត់ពលកម្មដោយបង្ខំពីចង្វាក់ផ្គត់ផ្គង់របស់ពួកគេ។ វេទិកាផ្តល់ជាគំរូដល់ពួកគេដើម្បីកំណត់អត្តសញ្ញាណអ្នកផ្គត់ផ្គង់ប្រកបដោយភាពប្រថុយប្រថានខ្ពស់ និងដើម្បីបង្កើតនូវគំហើញគ្រប់គ្រងនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់។ ជាចុងក្រោយ ការងាររបស់អង្គការទស្សនៈពិភពលោកនៅប្រទេសអូស្ត្រាលីត្រូវបានពិចារណាជាពិសេសយុទ្ធនាការកុំជួញដូរជីវិត[13]របស់ខ្លួន ដែលអំពាវនាវដល់បុគ្គល រដ្ឋាភិបាល និងវិស័យឯកជនដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ យុទ្ធនាការនេះគឺស្វះស្វែងផ្តល់ព័ត៌មានដល់សាធារណៈជនអូស្ត្រាលីអំពីការជួញដូរមនុស្សអន្តរជាតិ និងថាតើយុទ្ធនាការនេះត្រូវបានបញ្ចូលទៅក្នុងជីវិត និងជម្រើសប្រើប្រាស់របស់ពួកគេយ៉ាងដូចម្តេច។ យុទ្ធនាការនេះលើកកម្ពស់ការគាំទ្រសិទ្ធិអ្នកប្រើប្រាស់ប្រកបដោយសីលធម៌ និងសកម្មភាពគាំទ្រជាក់ស្តែងដើម្បីឲ្យមានឥទ្ធិពលលើឥរិយាបថរបស់អ្នកប្រើប្រាស់ ធុរកិច្ច និងការអនុវត្តន៍របស់រដ្ឋាភិបាល។ យុទ្ធនាការនេះក៏លើកកម្ពស់ការអនុវត្តន៍ផ្គត់ផ្គង់ផ្នែកសាធារណៈ និងឯកជនប្រកបដោយទំនួលខុសត្រូវ និងផ្តល់ឲ្យក្រុមហ៊ុនខិតខំដោះស្រាយការវេងថប្រវ័ញ្ចពលកម្មនៅក្នុងចង្វាក់ផ្គត់ផ្គង់របស់ពួកគេជាមួយនឹងមគ្គុទេសន៍ជាក់លាក់ និងច្បាស់លាស់។

## ឆ. វគ្គ៧: តើយើងចេញដំណើរពីចំណុចនេះឆ្ពោះទៅទីកន្លែងណា? ជំហានបន្ទាប់នៅក្នុងការចូលរួមរបស់ខ្សែសង្វាក់ផ្គត់ផ្គង់

20. នៅអំឡុងវគ្គចុងក្រោយនៃកិច្ចពិគ្រោះយោបល់នេះ សិក្ខាកាមបានសម្លឹងមើលទៅជំហានបន្ទាប់នៅក្នុងការជាប់ពាក់ព័ន្ធនៃខ្សែសង្វាក់ផ្គត់ផ្គង់ និងពិចារណាលើសំណួរថា៖ "តើយើងទៅទីណាពីទីនេះ?"។ គោលបំណងនៃវគ្គនេះគឺត្រូវស្វែងរកជំហានចាំបាច់បន្ទាប់សម្រាប់ការចូលរួមរបស់ធុរកិច្ច និងពហុភាគីធ្វើការជាប់ពាក់ព័ន្ធ ដើម្បីពិចារណា

[12] មើល http://slaveryfootprint.org/ and http://madeinafreeworld.com/.
[13] មើល www.donttradelives.com.au.

លើភាពប្រឈមដ៏សំខាន់ និងទម្រង់ថ្មីនៃការជាប់ពាក់ព័ន្ធ និងដើម្បីពិភាក្សាលើចំណុចគោល និងមគ្គុទេសក៍ប្រកបដោយសក្ដានុពលដើម្បីលើកកម្ពស់ចង្វាក់ផ្គត់ផ្គង់ដែលមិនមានការជួញដូរ។ សិក្ខាកាមត្រូវបានផ្ដល់ជូននូវសេចក្ដីព្រាងនៃបញ្ជីត្រួតពិនិត្យស្ដីពីសូចនាករណ៍និងរង្វាស់មូលដ្ឋានសម្រាប់ធុរកិច្ច ដើម្បីវាយតម្លៃលើគ្រោះថ្នាក់នៃអំពើជួញដូរមនុស្ស និងពលកម្មដោយបង្ខំនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ (សូមមើលអត្ថបទបន្ថែមទី១)។ សេចក្ដីព្រាងនេះត្រូវបានវាយតម្លៃ និងកែតម្រូវដោយក្រុមការងារចំនួនបី លើមូលដ្ឋាននៃកិច្ចពិភាក្សាធំទូលាយ និងពិស្ដារនៃមាតិកា និងទម្រង់របស់សេចក្ដីព្រាងនេះ។

21. សូចនាករ និងរង្វាស់មូលដ្ឋានទាំងនេះ គឺមានបំណងបំពេញលើការផ្ដួចផ្ដើមគំនិតសំខាន់ៗ ដែលមានស្រាប់ និងត្រូវបានបង្កើតដោយសហគ្រាស និងអង្គការសង្គមស៊ីវិលដែលការផ្ដួចផ្ដើមគំនិតមួយចំនួនត្រូវបានពិភាក្សារួចហើយនៅវគ្គខាងលើ។ សិក្ខាកាមក៏ស្នើផងដែរថា នៅក្នុងផែនការរយៈពេលវែង សូចនាករ និងរង្វាស់មូលដ្ឋានគួរតែផ្សព្វផ្សាយអមជាមួយនឹងឯកសារណែនាំសម្រាប់អ្នកប្រើប្រាស់។ អ្នករាយការណ៍ពិសេសជឿជាក់ថា បណ្ដុំនៃសូចនាករ និងរង្វាស់មូលដ្ឋានអាចជាឧបករណ៍ដ៏មានតម្លៃសម្រាប់ធុរកិច្ច ដើម្បីជួយពួកគេឲ្យប្រឹងប្រែង ដោយយោងទៅតាមគោលការណ៍ណែនាំស្ដីពីធុរកិច្ច និងសិទ្ធិមនុស្ស នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់ខ្លួន សំដៅរកឱ្យឃើញ និងទប់ស្កាត់ករណីជួញដូរមនុស្ស។ ជាលទ្ធផល អ្នករាយការណ៍ពិសេសយល់ឃើញថាបញ្ជីត្រួតពិនិត្យជាឧបករណ៍ជាក់លាក់មួយ ដែលមានគោលបំណងប្រើប្រាស់ជាមូលដ្ឋាន និងបំពេញបន្ថែមលើគោលការណ៍ណែនាំនេះ។ លោកស្រីក៏មានទស្សនៈថា បើទោះជាវានៅមានលក្ខណៈជាសេក្ដីព្រាងក៏ដោយ ក៏ការលើកកម្ពស់បណ្ដុំសូចនករ និងរង្វាស់មូលដ្ឋាននៅក្នុងអាណត្តិរបស់លោកស្រី អាចកំណត់បន្ថែមលើទំនួលខុសត្រូវរបស់សាជីវកម្មចំពោះសិទ្ធិមនុស្ស និងជាពិសេសជាងនេះ ទៅលើអំពើជួញដូរមនុស្ស។

# អត្ថបទបន្ថែមទី១

## វង្វាស់មូលដ្ឋាន និងសូចនាករសម្រាប់ធានាឲ្យខ្សែសង្វាក់ផ្គត់ផ្គង់ផលិតកម្មចៀសផុតពីអំពើជួញដូរមនុស្ស

## សម្រាប់ការពិភាក្សានៅអំឡុងពេលកិច្ចប្រជុំអ្នកជំនាញ ដែលរៀបចំឡើងដោយអ្នករាយការណ៍ពិសេសអំពីការជួញដូរមនុស្ស ជាពិសេសលើស្ត្រី និងកុមារ

### ការជ្រើសរើង និងការបម្រើការងារដោយស្ម័គ្រចិត្ត

1. តើការងារទាំងអស់សុទ្ធតែត្រូវធ្វើឡើងដោយស្ម័គ្រចិត្តដែរឬទេ? និងថាតើកម្មករទាំងអស់មានសិទ្ធិបញ្ចប់កិច្ចសន្យាការងាររបស់ខ្លួនតាមរយៈការជូនដំណឹងត្រឹមត្រូវ និងមានមូលហេតុគ្រប់គ្រាន់ បានគ្រប់ពេលវេលាដោយគ្មានការពិន័យដែរឬទេ?

### ថ្លៃជ្រើសរើស

2. តើពលករត្រូវបង់ថ្លៃសម្រាប់ការជ្រើសរើស រួមមានថ្លៃធ្វើដំណើរ និងដំណើរការធ្វើឯកសារផ្លូវការដែរឬទេ?

3. តើពលករត្រូវតម្រូវឲ្យតម្កល់ប្រាក់ធានា ឬ ឬប្រភេទចំណាយផ្សេងៗ ឬការតម្កល់ប្រភេទផ្សេងៗទៀតដែលមិនមែនជាសាច់ប្រាក់ដែរឬទេ?

### កិច្ចសន្យាការងារ

4. តើពលករពិតជាត្រូវបានពន្យល់ដោយសង្ខេបអំពីរយៈពេល លក្ខខណ្ឌការងារ និងតម្រូវការជំនាញ ជាភាសាដែលពួកគេយល់ដែរឬទេ?

5. តើកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរស្របច្បាប់ត្រូវបានផ្តល់ឲ្យពលករជាភាសាកំណើតរបស់ពួកគេ ដោយពន្យល់យ៉ាងច្បាស់ពីសិទ្ធិ និងទំនួលខុសត្រូវរបស់ពួកគេដោយមានទាំងប្រាក់បៀវត្សរ៍ ម៉ោងធ្វើការ ការបង់ពន្ធ និងលក្ខខណ្ឌការងារដទៃទៀតទេ?

6.

ក្នុងករណីដែលបេក្ខជនដែលនឹងអាចក្លាយជាពលករមិនអាចអានឬសរសេរអក្សរបាន តើមានវិធានការសមស្របណាមួយត្រូវបានធ្វើឡើងពួកគេ ដើម្បីធានាថាពួកគេ

យល់ដឹង និងព្រមព្រៀងចំពោះរាល់ចំណុចទាំងអស់ ដែលកំណត់នៅក្នុងកិច្ចសន្យាដែរឬទេ?

7. តើពលករទេសន្តរប្រវេសន៍ត្រូវបានបង្ហាញនូវឯកសារនៃកិច្ចសន្យាការងារនៅដំណាក់កាលពិគ្រោះយោបល់ដំបូងនៅមុនមានការព្រមព្រៀង ឬផែនការបែងចែកការងារជាផ្លូវការដែរឬទេ?

8. តើអ្នកបានហាមឃាត់ការបង្កើតឱ្យមានជាកិច្ចសន្យាបន្ថែម និងការអនុវត្តកិច្ចសន្យាជំនួសដែរឬទេ?

9. តើការផ្លាស់ប្តូរកិច្ចសន្យាការងារត្រូវបានហាមឃាត់មិនឲ្យមានការកាត់បន្ថយប្រាក់បៀវត្សរ៍ ប្រាក់កម្រៃ និងលក្ខខណ្ឌការងារដទៃទៀត ដែលត្រូវបានកំណត់ពីមុនដែរឬទេ?

10. តើអ្នកបានត្រួតពិនិត្យលើទីភ្នាក់ងារអនុវត្តកិច្ចសន្យា និងកិច្ចសន្យាដទៃទៀតដែលពួកគេបានព្រមព្រៀងជាមួយពលករដែរឬទេ?

### ការដកហូតយកលិខិតឆ្លងដែន

11. តើការដកហូត ឬការកាន់កាប់ឯកសារសម្គាល់ខ្លួនរបស់ពលករ (ឧ: លិខិតឆ្លងដែនជាដើម) ត្រូវបានហាមឃាត់យ៉ាងតឹងរ៉ឹងដែរឬទេ?

12. ក្នុងករណីដែលនយោជកត្រូវរក្សាទុកឯកសាររបស់ពលករសម្រាប់មូលផលស្របច្បាប់ណាមួយ តើពលករមានសិទ្ធិទទួលបានឯកសាររបស់ពួកគេ (រួមមាន ឯកសារធ្វើដំណើរ អត្តសញ្ញាណប័ណ្ណ និងឯកសារពាក់ព័ន្ធនឹងការងារជាដើម) មកវិញនៅពេលណាក៏បានតាមការស្នើសុំដែរឬទេ?

### ការអនុវត្តប្រកបដោយមនុស្សធម៌

13. តើការប្រើប្រាស់ហិង្សា ឬការគំរាមកំហែងលើផ្លូវកាយ និងផ្លូវភេទ ការធ្វើទុក្ខបុកម្នេញ និងការបំភិតបំភ័យត្រូវបានហាមឃាត់ និងដាក់ទណ្ឌកម្មយ៉ាងតឹងរ៉ឹងដែរឬទេ?

14. ក្នុងករណីមានបញ្ហាកើតឡើង តើមាននីតិវិធីដោះស្រាយប្រកបដោយប្រសិទ្ធភាពដែរឬទេ?

### សមភាពការងារ

15. តើពលករទាំងអស់ត្រូវបានយកទុកដាក់បានត្រឹមត្រូវ និងដោយស្មើភាពគ្នា ដោយមិនមានការរើសអើងលើកត្តាផ្សេងៗ រួមមានភេទ យេនឌ័រ សញ្ជាតិ ជនជាតិ ការ

ចូលរួមក្នុងសហជីព និន្នាការនយោបាយ ជំនឿ និន្នាការភេទ ពិការភាព និងស្ថានភាព រស់នៅដែរឬទេ?

## ប្រាក់ឈ្នួល និងប្រាក់កម្រៃ

16. តើពលករត្រូវជំពាក់បំណុល ឬត្រូវបានបង្ខំឲ្យធ្វើការដើម្បីសងបំណុលប្រភេទណាមួយ រួមមានបំណុលមិនមែនជាប្រាក់ (ឧ: បំណុលមកពីការផ្តល់ឲ្យជាឧបករណ៍ ឬការបណ្តុះបណ្តាលជាដើម) ដែរឬទេ?

17. តើពលករត្រូវបានផ្តល់ប្រាក់ឈ្នួលជារូបិយប័ណ្ណស្របច្បាប់ និងទទួលបានសំបុត្របញ្ជាក់ឬបង្កាន់ដៃបើកប្រាក់ជាលាយលក្ខណ៍អក្សរ បញ្ជាក់ច្បាស់លាស់ (អំពីអត្រាប្រាក់បៀវត្សរ៍ ចំនួនម៉ោងបានធ្វើការ ទឹកប្រាក់សរុប និងការកាត់ប្រាក់ឈ្នួលដែលមានបញ្ញត្តិត្រឹមត្រូវតាមច្បាប់ធ្វើឡើងដោយនយោជក) ជាភាសាដែលពលករអាចយល់បានដែរឬទេ?

18. តើពលករត្រូវបានផ្តល់នូវប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗដែលកំណត់ដោយច្បាប់ដែរឬទេ?

19. តើប្រាក់ឈ្នួលត្រូវបានផ្តល់ឱ្យ ដោយផ្ទាល់ដៃដល់ពលករ និង/ឬ តាមរយៈគណនីធនាគាររបស់ពួកគេ ក្នុងរយៈពេលទៀងទាត់ ដោយមិនមានការពន្យាពេល ការព្យួរ ឬការរឹបអូសឃាត់ទុកដែរឬទេ?

20. តើការកាត់ប្រាក់ឈ្នួលរបស់ពលករធ្វើឡើងស្របតាមច្បាប់បញ្ញត្ត និងមិនហួសពីបរិមាណភាគជាចាំបាច់សម្រាប់ការចិញ្ចឹមជីវិតដែរឬទេ?

21. តើការផ្តល់ប្រាក់ឈ្នួលមុន ឬប្រាក់កម្ចី រួមទាំងអត្រាការប្រាក់ និងរយៈពេលត្រូវសង ត្រូវបានធ្វើឡើងត្រឹមត្រូវតាមច្បាប់ ក្រោយពេលដែលពលករទទួលបានការពិគ្រោះយោបល់ជាភាសាកំណើតរបស់ពួកគេ និងភាគីទាំងសងខាងបានព្រមព្រៀងគ្នាជាមុនដែរឬទេ?

22. តើពលករអាចរក្សាទុក និងគ្រប់គ្រងពេញលេញលើប្រាក់ឈ្នួលរបស់ពួកគេ និងមានសេរីភាពប្រើប្រាស់ប្រាក់ឈ្នួលតាមចិត្តរបស់ពួកគេដែរឬទេ?

## សេរីភាពក្នុងការធ្វើដំណើរ

23. តើពលករត្រូវបានកម្រិតព្រំដែនក្នុងការធ្វើដំណើរនៅកន្លែងធ្វើការ ឬពួកគេប្រឈមនឹងការរឹតបន្តឹង (រួមមានការបំភិតបំភ័យផ្លូវចិត្ត និង/ឬការគំរាមកំហែងតាមសម្តី) លើសេរីភាពបន្លាស់ទីរបស់ពួកគេនៅក្រៅម៉ោងធ្វើការ ឬនៅបរិវេណនៃកន្លែងស្នាក់នៅ ឬនិវេសនដ្ឋានរបស់ពួកគេដែរឬទេ?

### សេរីភាពនៃការបង្កើតសមាគម និងការចរចាជាសមូហភាព

24. តើពលករទាំងអស់ ដោយមិនគិតពីសញ្ជាតិ ឬស្ថានភាពរស់នៅរបស់ពួកគេ មានសិទ្ធិចូលរួមនៅក្នុងសហជីព និងចរចាជាសមូហភាពឬទេ?

### ក្របខ័ណ្ឌសម្រាប់ធានាឱ្យមានការអនុវត្តត្រឹមត្រូវ និងការត្រួតពិនិត្យ

25. តើអ្នកមានគោលនយោបាយ និងក្រមសីលធម៌ត្រឹមត្រូវ ដែលហាមឃាត់ជាក់លាក់ទៅលើគ្រប់ទម្រង់នៃការជួញដូរមនុស្សដែរឬទេ?

26. តើអ្នកមានប្រព័ន្ធគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាព ដើម្បីគាំទ្រដល់ការអនុវត្តន៍គោលនយោបាយប្រឆាំងការជួញដូរមនុស្សដែរឬទេ?

27. តើអ្នកបានដឹងអំពីដំណើរការនៃការធ្វើកិច្ចសន្យាបន្តនៅក្នុងក្រុមហ៊ុន និងក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់អ្នកដែរឬទេ?

28. តើអ្នកធ្វើការវាយតម្លៃគ្រប់ជ្រុងជ្រោយលើខ្សែសង្វាក់ផ្គត់ផ្គង់ និងព្យាយាមត្រួតពិនិត្យលើលក្ខខណ្ឌជ្រើសរើស និងបម្រើការងារដែលអនុវត្តនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់អ្នក រួមទាំងទីភ្នាក់ងារអនុវត្តកិច្ចសន្យាបន្តដែរឬទេ?

29. តើបុគ្គលិកផ្នែកធនធានមនុស្ស ផ្នែកត្រួតពិនិត្យប្រតិបត្តិការសង្គម និងបុគ្គលិកពាក់ព័ន្ធដទៃទៀតរបស់អ្នកត្រូវបានបណ្តុះបណ្តាលអំពីគ្រោះថ្នាក់ និងសញ្ញាណនៃការជួញដូរមនុស្ស និងគោលនយោបាយ និងនីតិវិធីរបស់ក្រុមហ៊ុនក្នុងការប្រឆាំងការជួញដូរមនុស្សដែរឬទេ?

30. តើករណីជួញដូរមនុស្សនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ត្រូវបានរកឃើញនៅកន្លែងណាខ្លះ? តើសុខុមាលភាព និងផលប្រយោជន៍សំខាន់បំផុតរបស់ពលកររងគ្រោះត្រូវបានចិត្តទុកដាក់មុនគេ និងចាត់ទុកជាបញ្ហាសំខាន់ដែរឬទេ? តើមានយន្តការបញ្ជូនទៅរកសេវា និងការទទួលបានសំណងដល់ជនរងគ្រោះដែរឬទេ?

31. តើអ្នកបានបង្កើតយន្តការបណ្តឹងតវ៉ាលក្ខខណ្ឌការងារប្រកបដោយប្រសិទ្ធភាព និងអាចជឿទុកចិត្តបាន ដើម្បីឲ្យពលករអាចបញ្ចេញពីកង្វល់ទាក់ទងនឹងលក្ខខណ្ឌជ្រើសរើសនិងបម្រើការងារ រួមទាំងគោលនយោបាយរាយការណ៍ព័ត៌មានដែលធានារក្សាការសម្ងាត់ជូនពលករដែលរាយការណ៍ក្រោមលក្ខខណ្ឌមិនបញ្ចេញឈ្មោះដែរឬទេ?

32. តើអ្នកបានរាយការណ៍ដោយចំហ និងធ្វើទំនាក់ទំនងទៀងទាត់ជាមួយភាគីពាក់ព័ន្ធផ្សេងៗ (រួមទាំងវិនិយោគិន)អំពីគោលនយោបាយ កម្មវិធី ដំណើរការអនុវត្តន៍ និងផលវិបាកទាក់ទងនឹងការ ប្រឆាំងការជួញដូរមនុស្សដែរឬទេ?

33. តើអ្នកមានទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធដទៃទៀតដើម្បីប្រែក្លាយការប្តេជ្ញាចិត្តប្រឆាំងការជួញដូរមនុស្សរបស់ក្រុមហ៊ុនទៅជាសកម្មភាពពិតប្រាកដដែរឬទេ?

34. តើអ្នកមានទំនាក់ទំនងជាមួយរដ្ឋាភិបាល និងស្ថាប័នសាធារណៈដទៃទៀត រួមទាំងអង្គការអន្តរជាតិ ដើម្បីទាមទារឱ្យមានកំណែទម្រង់ច្បាប់ បទបញ្ញា និងគោលនយោបាយជាបន្តបន្ទាប់សំដៅគាំទ្រវិធានការប្រឆាំងការជួញដូរមនុស្សដែរឬទេ?

# អត្ថបទបន្ថែមទី២

## របៀបវារៈនៃកិច្ចពិគ្រោះយោបល់អ្នកជំនាញ ស្ដីពីការជួញដូរមនុស្ស និងខ្សែសង្វាក់ផ្គត់ផ្គង់នៅលើពិភពលោក

## ការជួញដូរមនុស្ស និងខ្សែសង្វាក់ផ្គត់ផ្គង់នៅលើពិភពលោក ទីក្រុងអង់ការ៉ា ថ្ងៃទី១២ និង១៣ ខែវិច្ឆិកា ឆ្នាំ២០១២

## ថ្ងៃចន្ទ ទី១២ ខែវិច្ឆិកា

9–9.30 ព្រឹក **មតិស្វាគមន៍ និងសុន្ទរកថាបើកកិច្ចប្រជុំ**

**គោលបំណងនៃកិច្ចប្រជុំ**

មតិស្វាគមន៍ដោយអ្នកតំណាងប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិ លោក សាហ៊ិត ណាចាម

សេចក្ដីផ្ដើម និងគោលបំណងនៃកិច្ចប្រជុំ
អ្នករាយការណ៍ពិសេសស្ដីពីការជួញដូរមនុស្ស ជាពិសេសលើស្ត្រី និងកុមារ - លោកស្រី ចយ ង៉ូហ្ស៊ី អេហ្សីឡូ

9.30–11.15 ព្រឹក **វគ្គ១**

**ការជួញដូរមនុស្ស និងខ្សែសង្វាក់ផ្គត់ផ្គង់នៅលើពិភពលោក: ការយល់ដឹងពីបញ្ហាប្រឈម និងហានិភ័យទៅលើផ្នែកធុរកិច្ច និងពលករ**

**គោលបំណងនៃវគ្គ១:**

- ដើម្បីកំណត់ថាតើការជួញដូរមនុស្សកើតឡើងបានយ៉ាងដូចម្ដេច ដោយមូលហេតុអ្វី និងនៅត្រង់ណាខ្លះ នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ និងដើម្បីយល់ដឹងពីគ្រោះថ្នាក់ ដែលកើតមានចំពោះពលករ និងផ្នែកធុរកិច្ចដែលត្រូវបានធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចសាកលលោក។
- ដើម្បីយល់ដឹងកាន់តែច្បាស់អំពីកាលានុវត្តភាព និងបញ្ហាប្រឈម ដែលស្ថាប័នធុរកិច្ចជួបប្រទះក្នុងពេលឆ្លើយតបទៅនឹងការជួញដូរមនុស្ស។

ដោយសម្របតាមគោលបំណងនៃវគ្គនេះ វាគ្មិននីមួយៗនឹងពិភាក្សាលើលក្ខណៈនៃការជួញដូរមនុស្សនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់នៅលើពិភពលោក: ថាតើបញ្ហានេះស្តែងឡើងដោយខ្លួនឯងបានយ៉ាងដូចម្តេច ហើយនិងទម្រង់រួមផ្សំសំខាន់ៗនៃការរំលោភបំពាន រួមបញ្ចូលទាំងរូបភាពលម្អិតនៃពលកម្មដោយបង្ខំ និងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។ល។

*អ្នកសម្របសម្រួល: លោកស្រី កាថារីន ចូន នៃវិទ្យាស្ថានធុរកិច្ច និងសិទ្ធិមនុស្ស*

- លោកស្រី ម៉ារី អាប៉ូស្តូល មកពីក្រុមហ៊ុន«គំនិតផ្តួចផ្តើមជ្រើសរើសឱ្យបម្រើការងារសមរម្យ»
- លោកស្រី ចូណា អេវើត ជេមស៍ មកពីអង្គការ«ប្រឆាំងទាសភាពអន្តរជាតិ»
- លោក ជេរ៉ូអែន បេណឹត មកពីសហព័ន្ធសហជីពអន្តរជាតិ
- លោកស្រី ប៊ីស៊ី អូឡាតេរូ អូឡាកបេហ្គី មកពីបណ្តាញសមាគមនារីនីហ្សេរីយ៉ា

*កិច្ចពិភាក្សា*

11.15–11.45 ព្រឹក **សម្រាក**

11.45 ព្រឹក–1 រសៀល **វគ្គ២**

**ការបង្កើតល្បែងទី១: ការឆ្លើយតបនៃផ្នែកធុរកិច្ចចំពោះហានិភ័យពាក់ព័ន្ធនឹងការជួញដូរមនុស្ស**

**គោលបំណងនៃវគ្គ២:**

- ដើម្បីស្វែងរកវិធីផ្សេងៗ ដែលផ្នែកធុរកិច្ចបានឆ្លើយតបទៅនឹងការជួញដូរមនុស្ស រួមមានការឆ្លើយតបរបស់ក្រុមហ៊ុន ឧស្សាហកម្ម និងផ្នែកពាក់ព័ន្ធចម្រុះ។
- ដើម្បីលើកយកគំរូពីផ្នែកផ្សេងៗ ដូចជាវិស័យបច្ចេកវិជ្ជាទូរគមនាគមន៍និងព័ត៌មាន និងវិស័យកាត់ដេរជាដើម។
- ដើម្បីបង្ហាញជាមេរៀនសម្រាប់កម្មវិធីប្រឆាំងការជួញដូរមនុស្សដ៏មានប្រសិទ្ធភាព ដែលអនុវត្តដោយផ្នែកធុរកិច្ច។

នៅក្នុងវគ្គនេះ វាគ្មិននីមួយៗនឹងពន្យល់អំពីរបៀបដែលក្រុមហ៊ុនរបស់ពួកគេបានឆ្លើយតបទៅនឹងហានិភ័យពាក់ព័ន្ធនឹងការជួញដូរមនុស្សនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់ខ្លួន និងកិច្ចការដែលពួកគេបានធ្វើអ្វីដើម្បីជំនះលើបញ្ហាប្រឈមទាំងនោះ។ ប្រធានបទក្នុងវគ្គនេះរួមមាន៖ ការចូលរួមរបស់ទីភ្នាក់ងារផ្គត់ផ្គង់ ហានិភ័យទាក់ទងនឹងឈ្មួញកណ្តាលដែលធ្វើការជ្រើសរើសកម្លាំងពលកម្ម ការចូលរួមរបស់វិស័យឧស្សាហកម្ម និងអ្នកពាក់ព័ន្ធចម្រុះ (ដូចជាការចូលរួមក្នុងសម្ព័ន្ធពលរដ្ឋចម្រុះក្នុងវិស័យ

ឧស្សាហកម្មអេឡិចត្រូនិច) ហើយនិងគោលនយោបាយថ្មី បែបបទសវនកម្មសង្គម និងលិខិតុបករណ៍ដទៃទៀត។

*អ្នកសម្របសម្រួល: លោក ដេវីដ អាកឡេស មកពីក្រុមហ៊ុន«ហាត្តពលិក»*

- លោក កាល ដូម្វអ៊ែលលើរ មកពីក្រុមហ៊ុន«ហ្វ៊ឡេត ភេកខាដ»
- លោក ចេហ្វហ្វ្រី អាវីណា មកពីក្រុមហ៊ុម«ម៉ៃក្រូសូហ្វ»

*កិច្ចពិភាក្សា*

1 – 2 រសៀល **សម្រាកអាហារថ្ងៃត្រង់**

2 – 3.45 រសៀល. **វគ្គ៣**

**ការបង្កើតល្បែងទី២: ការឆ្លើយតបផ្នែកធុរកិច្ចចំពោះហានិភ័យទាក់ទងនឹងការជួញដូរមនុស្ស: ទស្សនៈនៃការជ្រើសរើសបុគ្គលិកប្រកបដោយក្រមសីលធម៌**

**គោលបំណងនៃវគ្គ៣:**

- ដើម្បីពិចារណាលើការឆ្លើយតបចំពោះការជួញដូរមនុស្សពីទីភ្នាក់ងារការងារឯកជននៅកម្រិតអន្តរជាតិ និងវិស័យឧស្សាហកម្ម។
- ដើម្បីត្រួតពិនិត្យលើតួនាទីរបស់សមាគមឧស្សាហកម្ម និងជំនួញនៅក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។
- ដើម្បីបង្ហាញពីការយល់ដឹងជាក់ស្តែង គំរូ និងមេរៀន ដែលបានរៀនសូត្រពីវិស័យជ្រើសរើស និងចាត់ចែងឱ្យបម្រើការងារប្រកបដោយក្រមសីលធម៌។

ជាកិច្ចបន្តពីវគ្គមុន វគ្គនេះនឹងបង្ហាញពីការចូលរួមអនុវត្តន៍ដ៏ល្អនៃវិស័យឧស្សាហកម្មយ៉ាងជាក់លាក់មួយ: គឺទីភ្នាក់ងារជ្រើសរើសឯកជន។ វាគ្មិននៃវគ្គនេះនឹងលើកឡើងពីទស្សនៈនៃ"ការជ្រើសរើសប្រកបដោយក្រមសីលធម៌" ដែលជាកត្តាដ៏សំខាន់នៅក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងពិភាក្សាពីតួនាទីរបស់សមាគមឧស្សាហកម្ម និងជំនួញ ជាពិសេសលើកំណែទម្រង់គោលនយោបាយ និងបទបញ្ញា។

*អ្នកសម្របសម្រួល: លោកស្រី ម៉ារី អាប៉ូស្តូល មកពីក្រុមហ៊ុន«គំនិតផ្តួចផ្តើមជ្រើសរើសឱ្យបម្រើការងារសមរម្យ»*

- លោក ដេវីដ អាកឡេស មកពីក្រុមហ៊ុន«ក្រុមហាត្តពលិក»
- លោក និក ហ្វសស្ទ័រ មកពីក្រុមហ៊ុន«អេហ្វអេសអាយ វើលវ៉ាយ»
- លោក ហ្វីលីប ហាន់ធើរ មកពីអង្គការ«តថភាព»
- បណ្ឌិត កាថារីន ចូន មកពីវិទ្យាស្ថានសិទ្ធិមនុស្ស និងធុរកិច្ច

*កិច្ចពិភាក្សា*

3.45–4.15 ល្ងាច **សម្រាក**

4.15–5.45 ល្ងាច **វគ្គ៤**

**ការបង្កើតល្បែងទី៣: ភាពជាដៃគូ និងកិច្ចសន្ទនាប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស**

**គោលបំណងនៃវគ្គ៤:**

- ដើម្បីស្វែងរកវិធីសាស្ត្របង្កើតភាពជាដៃគូនៅក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបញ្ហាប្រឈម និងកាលានុវត្តភាពវិធីសាស្ត្រទាំងនេះនៅក្នុងផ្នែកធុរកិច្ច។
- ដើម្បីវាយតម្លៃលើតួនាទីនៃកិច្ចសន្ទនាសង្គម និងការចូលរួមនៃអ្នកពាក់ព័ន្ធចម្រុះក្នុងការដោះស្រាយបញ្ហាជួញដូរមនុស្ស។

ឆ្លងតាមរយៈការស្ទង់មតិលើការចូលរួមរបស់ផ្នែកធុរកិច្ច វគ្គនេះត្រូវបានរៀបចំឡើងដើម្បីពិភាក្សាលើបញ្ហាប្រឈម និងកាលានុវត្តភាពទាំងឡាយ ដែលបង្ហាញដោយដៃគូធុរកិច្ច និងអ្នកពាក់ព័ន្ធចម្រុះ។

*អ្នកសម្របសម្រួល: លោក ជើរ៉ូអ៊ែន ប៉ែរណឹត មកពីសហព័ន្ធសហជីពអន្តរជាតិ*

- លោកស្រី ក្លារ៉ា ប៉ាស្គូល ដឺ វ៉ាហ្គាស មកពី«យុទ្ធនាការបញ្ចប់ការជួញដូរមនុស្សឥឡូវនេះ»
- លោកស្រី លីសា រេន ថាយល័រ មកពី«គម្រោងអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិប្រឆាំងនឹងអំពើជួញដូរមនុស្ស»
- លោក ដេវីដ ប៉ែតស្គួន មកពីអង្គការ«មិនមែនសម្រាប់លក់»

*កិច្ចពិភាក្សា*

5.45–6 ល្ងាច **សង្ខេបខ្លឹមសារថ្ងៃទី១**

## ថ្ងៃអង្គារ ទី១៣ ខែវិច្ឆិកា

9–10.30 ព្រឹក **វគ្គ៥**

**បទដ្ឋានអន្តរជាតិ និងគោលនយោបាយសាធារណៈ ដែលឆ្លើយតបទៅនឹងការជួញដូរមនុស្ស និងខ្សែសង្វាក់ផ្គត់ផ្គង់**

**គោលបំណងនៃវគ្គ៥:**

- ដើម្បីយល់ដឹងពីបរិបទនៃនិយាមអន្តរជាតិទាក់ទងការចូលរួមរបស់ផ្នែកធុរកិច្ច និងខ្សែសង្វាក់ផ្គត់ផ្គង់ក្នុងការប្រឆាំងការជួញដូរមនុស្ស។
- ដើម្បីពិចារណាលើតួនាទីរបស់ស្ថាប័នរដ្ឋាភិបាល និងស្ថាប័នអន្តររដ្ឋាភិបាល នៅក្នុងកិច្ចពិភាក្សាស្តីពីការចូលរួមរបស់ផ្នែកធុរកិច្ចក្នុងការប្រឆាំងការជួញដូរមនុស្ស។
- ដើម្បីបង្ហាញពីគំរូនៃគោលនយោបាយសាធារណៈ ដែលឆ្លើយតបទៅនឹងការជួញដូរមនុស្ស និងពលកម្មដោយបង្ខំនៅក្នុងសេដ្ឋកិច្ចសាកលោក និងដើម្បីបង្កើនការយល់ដឹងទៅលើកិច្ចការរបស់អ្នកកសាងគោលនយោបាយសាធារណៈ ក្នុងការងារដោះស្រាយបញ្ហាជួញដូរមនុស្សនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់។

វគ្គនេះនឹងត្រួតពិនិត្យលើនិយាមដែលបង្កើតឡើងដោយអង្គការពលកម្មអន្តរជាតិ និងដោយអង្គការសហប្រជាជាតិទាក់ទងនឹងការជួញដូរមនុស្ស និងពលកម្មដោយបង្ខំ ព្រមទាំងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្សដែលទើបនឹងអនុម័តនាពេលថ្មីៗនេះ។ វាគ្និននឹងពិភាក្សាថាតើពួកគេជាប់ពាក់ព័ន្ធនឹងខ្សែសង្វាក់ផ្គត់ផ្គង់នៅលើពិភពលោកយ៉ាងដូចម្តេច និងថាតើរដ្ឋាភិបាល និងស្ថាប័នអន្តររដ្ឋាភិបាលបានឆ្លើយតបចំពោះបញ្ហានេះយ៉ាងដូចម្តេច។

*អ្នកសម្របសម្រួល: លោកស្រី ខេត សេល មកពី«សម្ព័ន្ធភាពសាកលដើម្បីប្រឆាំងការជួញដូរស្ត្រី»*

- អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសលើស្ត្រី និងកុមារ លោកស្រី ចយ ង៉ូហ្ស៊ី អេហ្សីឡូ
- លោកស្រី ម៉េលថេម អេសយ មកពីអង្គការទេសន្តរប្រវេសន៍អន្តរជាតិប្រចាំប្រទេសទួរគី

*កិច្ចពិភាក្សា*

10.30–11 ព្រឹក. **សម្រាក**

11 -12.30 ថ្ងៃត្រង់ **វគ្គ៦**

**យុទ្ធសាស្ត្រថ្មីសម្រាប់ខ្សែសង្វាក់ផ្គត់ផ្គង់ និងការចូលរួមរបស់អ្នកប្រើប្រាស់**

**គោលបំណងនៃវគ្គ៦:**

- ដើម្បីត្រួតពិនិត្យលើការផ្តួចផ្តើមថ្មីដើម្បីលើកកម្ពស់ការចូលរួមប្រឆាំងការជួញដូរមនុស្សពីសំណាក់ខ្សែសង្វាក់ផ្គត់ផ្គង់ និងអ្នកប្រើប្រាស់។

- ដើម្បីបង្ហាញពីលិខិតុបករណ៍បច្ចេកទេសនិងមានលក្ខណៈជានិយាមដែលទើបបង្កើតថ្មីៗសម្រាប់ជួយផ្នែកធុរកិច្ចនៅក្នុងកិច្ចខិតខំប្រឹងប្រែងដោះស្រាយបញ្ហាជួញដូរមនុស្សនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់។
- ដើម្បីធ្វើការស្ទង់មតិទៅលើវិធីសាស្ត្រផ្តោតជាសំខាន់លើអ្នកប្រើប្រាស់ និងបច្ចេកទេសព័ត៌មានវិទ្យាក្នុងការប្រឆាំងការជួញដូរមនុស្ស។

ដោយពិនិត្យលើគោលការណ៍ និងការផ្តួចផ្តើមគំនិតមានស្រាប់ ដែលបង្កើតដោយរដ្ឋ និងផ្នែកធុរកិច្ច វគ្គនេះនឹងផ្តោតលើការផ្តួចផ្តើមគំនិត និងយុទ្ធសាស្ត្រថ្មី ដែលដឹកនាំដោយអង្គការមិនមែនរដ្ឋាភិបាល និងអ្នកប្រើប្រាស់ និងពិភាក្សាលើតួនាទីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់។

*អ្នកសម្របសម្រួលៈ លោក ដេវីដ ប៉ែតស្ទូន មកពីអង្គការ«មិនមែនសម្រាប់លក់»*

- លោកស្រី អាណាស្តាសៀ សាហ្គូឡាម មកពីអង្គការទេសន្តរប្រវេសន៍អន្តរជាតិប្រចាំប្រទេសទួរគី
- លោក ចាស្ទីន ឌិលឡុន មកពីអង្គការ«ស្នាមជើងទាសភាព»
- លោកស្រី ម៉េលីសសា ស្តេវ៉ាត មកពីអង្គការទស្សនៈពិភពលោកប្រចាំប្រទេសអូស្ត្រាលី

*កិច្ចពិភាក្សា*

12.30–2 រសៀល **សម្រាកទទួលទានអាហារថ្ងៃត្រង់**

2–3.30 រសៀល **វគ្គ៧**

**តើយើងនឹងចាកចេញពីចំណុចនេះឆ្ពោះទៅកាន់កន្លែងណាខ្លះ?**
**ជំហានបន្ទាប់សម្រាប់ការចូលរួមរបស់ខ្សែសង្វាក់ផ្គត់ផ្គង់**

**គោលបំណងនៃវគ្គ៧:**

- ដើម្បីស្រាវជ្រាវរកជំហានបន្ទាប់ចាំបាច់សម្រាប់ការចូលរួមនៃផ្នែកធុរកិច្ច និងអ្នកពាក់ព័ន្ធចម្រុះក្នុងការប្រឆាំងការជួញដូរមនុស្ស។
- ដើម្បីពិចារណាលើបញ្ហាប្រឈមដ៏សំខាន់ និងទម្រង់ថ្មីនៃការចូលរួមជម្នះបញ្ហាប្រឈមទាំងនោះ។
- ដើម្បីពិភាក្សាលើបទដ្ឋាន និងសូចនាករដែលមាន សម្រាប់លើកកម្ពស់ខ្សែសង្វាក់ផ្គត់ផ្គង់ដែលអាចចៀសផុតពីការជួញដូរមនុស្ស។

វគ្គនេះត្រូវបានរៀបចំដើម្បីចាប់ផ្តើមសង្ខេបកិច្ចពិភាក្សាពីវគ្គមុនៗ ដើម្បីកំណត់ថាតើអ្វីដែលគួរជាជំហានបន្ទាប់ និងគោលដៅរយៈពេលវែងសម្រាប់ការចូលរួមប្រឆាំងការជួញដូរមនុស្សពីសំណាក់ផ្នែកធុរកិច្ច។ វគ្គនេះក៏ជាឱកាសដើម្បីពិចារណាលើការបង្កើតបទដ្ឋាន និងសូចនាករ សម្រាប់លើកកម្ពស់ខ្សែសង្វាក់ផ្គត់ផ្គង់ដែលអាចចៀសផុតពីការជួញដូរមនុស្ស។

*អ្នកសម្របសម្រួលៈ អ្នករាយការណ៍ពិសេសស្តីពីការជួញដូរមនុស្ស ជាពិសេសលើស្ត្រី និងកុមារ លោកស្រី ចយ ង៉ូហ្ស៊ី អេហ្សីឡូ*

*កិច្ចពិភាក្សាទូលាយ*

3.30–4 ល្ងាច. **សម្រាក**

4–5 ល្ងាច **សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

ការប្រមូលផ្តុំគំនិតៈ អនុសាសន៍ និងជំហានបន្តខ

សុន្ទរកថាបិទ